**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Dec-2010, 14:38
CMS/CFO: Kau Keoratanak

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណាបណ្ដឹងសាទុក្ខ របស់សហមេធាវីការពារក្ដីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

---

| <u>អ្នកដាក់ឯកសារ:</u> | <u>អ្នកទទួលឯកសារ:</u> | |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះតុលាការកំពូល:** | **មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:** |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រីម, ប្រធាន | លោក គង់ ពិសី |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | លោក ហុង គីមសួន |
| | ចៅក្រម សោម សិរីវឌ្ឍ | លោក យុង ផានិត |
| | ចៅក្រម A. KLONOWIECKA MILART | លោក គឹម ម៉េងឃី |
| | ចៅក្រម ស៊ិន រិទ្ធ | កញ្ញា ម៉ុច សុវណ្ណារី |
| | ចៅក្រម C. N. JAYASINGHE | កញ្ញា SILKE Studzinsky |
| | ចៅក្រម យ៉ា ណារិន | លោកស្រី Martine JACQUIN |

*សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក*

| | |
|---|---|
| | លោក Philippe CANONNE |
| **មេធាវីការពារក្ដីរបស់ជនជាប់ចោទ** | លោកស្រី ទី ស្រ៊ីនណា |
| **ឈ្មោះ** កាំង ហ្កេកអ៊ាវ ហៅ ឌុច : | លោក Pierre Olivier SUR |
| លោក ការ សាវុត្ថ | លោក Alain WERNER |
| លោក កង ឫទ្ធារី | លោកស្រី Brianne McGONOGLE |
| | លោកស្រី Annie DELAHAIE |
| | លោកស្រី Elizabeth RABESANDRATANA |
| | លោក Karim KHAN |
| | លោកស្រី Fabienne TRUSSES-NAPROUS |

# មាតិកា

១. សេចក្ដីផ្ដើម ........................................ 4

២. ចម្លើយតបទៅនឹងទឡ្ហីករណ៍ទី១៖ អង្គជំនុំជម្រះសាលាដំបូងមិន បានភាន់ ច្រឡំអំពី "យុត្តាធិការបុគ្គល" នោះឡើយ ........................................ 13

ក. អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងការសម្រេចថាការជំទាស់អំពីយុត្តាធិការបុគ្គលរបស់ដើមបណ្ដឹងសាទុក្ខ ធ្វើឡើងមិនចំពេលវេលា និងថាបើដូច្នេះមិនអាចទទួលយកបាន ........................................ 14

i. បទដ្ឋាននៃការត្រួតពិនិត្យ ........................................ 14

ii. ការពិភាក្សា ........................................ 15

ខ. អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងការបកស្រាយមាត្រា១ និងមាត្រា២នៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង ដែលកំណត់ជំពូកមនុស្សពីរដាច់ពីគ្នាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ........................................ 20

i. បទដ្ឋាននៃការត្រួតពិនិត្យ ........................................ 22

ii. ការពិភាក្សា ........................................ 22

គ. អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងការរកឃើញថា ខ្លួនមានយុត្តាធិការទៅលើដើមបណ្ដឹងសាទុក្ខ សំអាងលើឋានៈរបស់គាត់ជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ........................................ 26

i. បទដ្ឋាននៃការត្រួតពិនិត្យ ........................................ 28

ii. ការពិភាក្សា ........................................ 30

៣. ចម្លើយតបទៅនឹងទឡ្ហីករណ៍ទី២៖អង្គជំនុំជម្រះសាលាដំបូង មិនមានការភាន់ច្រឡំ "ចំពោះការផ្ដន្ទាទោស" ........................................ 43

ក. ទឡ្ហីករណ៍ទី២ នៃបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី គឺមិនមែនជាទឡ្ហីករណ៍ដាច់ដោយឡែកនៃបណ្ដឹងសាទុក្ខទេ ហើយគួរតែត្រូវបានបដិសេធចោល ដោយសារមូលហេតុដូចគ្នា ទៅនឹងទឡ្ហីករណ៍ទី១ នៃបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ........................................ 45

ខ. អង្គជំនុំជម្រះសាលាដំបូង មិនមានការភាន់ច្រឡំ ដោយខកខានមិនបានពិចារណាទៅលើ ភស្ដុតាង "ដោះបន្ទុក" ទេ ........................................ 47

៤. សេចក្ដីសន្និដ្ឋាន ........................................ 51

# ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញា សន្និដ្ឋានថា ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីឱ្យឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **"ឌុច"** ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី") ដោយអនុលោមតាមមាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ("សេចក្តីណែនាំអនុវត្ត")[1]។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា នេះគឺមានលក្ខណៈទាន់ពេលវេលា ដោយហេតុថាសហព្រះរាជអាជ្ញាបានស្នើសុំ និងបានទទួលនូវការពន្យារពេលបន្ថែមចំនួនដប់ប្រាំ(១៥)ថ្ងៃ នៃពេលវេលាដែលត្រូវបានកំណត់ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខនេះ[2] ។

២. បញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះ គឺមិនមែនជាពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទទេ។ ដើមបណ្តឹងសាទុក្ខ ធ្លាប់បានទទួលសារភាពពីការទទួលខុសត្រូវរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ដែលបានកើតឡើងនៅក្រោមការពិនិត្យពិច័យ និងការដឹកនាំរបស់ខ្លួនយ៉ាងជិតដិត។ វាក៏មិនមានបញ្ហាណាមួយដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះស្តីពីរយៈពេលនៃការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ដែលជនជាប់ចោទត្រូវបំពេញនោះ ក៏ទេដែរ[3]។

---

[1] សេចក្តីណែនាំអនុវត្ត, មាត្រា ៨.៣ ។

[2] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី៧ ធ្នូ ២០១០, F14/3 ។

[3] បញ្ហានេះត្រូវបានពិភាក្សាយ៉ាងពិស្តារនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ។ *សូមមើល* បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជតក, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី១៣ តុលា ២០១០, F10 [បន្ទាប់ពីនេះទៅហៅថា៖ "សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា"], កថាខណ្ឌទី ៨-៤៥ ។

៣. ផ្ទុយទៅវិញ បញ្ហាដែលបានលើកឡើងដោយដើមបណ្តឹងសាទុក្ខនោះគឺថាតើ អវតក មានសិទ្ធិអំណាចនៅក្នុងការចោទប្រកាន់លើរូបគាត់ដែរឬទេ - និយាយម្យ៉ាងវិញទៀតគឺថាតើ អវតក មានសិទ្ធិអំណាចធ្វើការផ្តន្ទាទោសលើរូបគាត់ចំពោះអំពើឧក្រិដ្ឋរបស់គាត់ដែរឬទេ។ ដើមបណ្តឹងសាទុក្ខអះអាងថា អង្គជំនុំជម្រះនេះមិនមានសិទ្ធិអំណាចនេះទេ។ គាត់បានអះអាងថា អវតក ខ្វះយុត្តាធិការបុគ្គលទៅលើរូបគាត់ ហើយគាត់មិនយល់ព្រមទៅនឹងបទដ្ឋានដែលតម្រូវឱ្យមាននោះ ទេ ពីព្រោះ "គាត់មិនត្រូវបានចាត់ថ្នាក់នៅក្នុងរចនាសម្ព័ន្ធដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃកម្ពុជាប្រជាធិបតេយ្យទេ"[4]។ ដើមបណ្តឹងសាទុក្ខបានធ្វើសេចក្តីសន្និដ្ឋានចុងក្រោយនៅក្នុងសារណារបស់ខ្លួន ដោយទទូចអះអាងថា ដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០១ គួរត្រូវបានចាត់ទុកថាជា "ការជំនុំជម្រះភាន់ច្រឡំ", ការឃុំខ្លួនរបស់គាត់ត្រូវបានចាត់ទុកថាជា "កិច្ចរក្សាការពារសាក្សីមានសក្តានុពល" ហើយថាគាត់ត្រូវតែបានដោះ លែង[5]។

៤. សារណារបស់ដើមបណ្តឹងសាទុក្ខនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺមានការមិនស្របទៅនឹងជំហរដែលគាត់បានប្រកាន់យកនៅពេលចាប់ផ្តើមដំបូង និងនៅក្នុងភាគច្រើននៃដំណើរការនីតិវិធីនៃសំណុំរឿងលេខ០០១។ ជាបញ្ហាច្បាប់ ក៏មិនត្រូវបានគាំទ្រផងដែរ។

4 សារណារបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អវតក/អជតក, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី១៨ វិច្ឆិកា ២០១០, F14 [បន្ទាប់ពីនេះទៅហៅថាៈ "សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី"], កថាខណ្ឌទី ២២ ។ ដើមបណ្តឹង សាទុក្ខលើកឡើងឆ្ងាយពីនេះទៀតរហូតដល់ទៅអះអាងថាខ្លួនគាត់ធ្លាប់ជា "អ្នកទទួលខុសត្រូវតិចបំផុត" ក្នុងចំណោមអ្នកទទួលខុសត្រូវ តិចបំផុតនានា ។ *ដូចមុនដដែល*, កថាខណ្ឌទី ២២ ។

5 សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ១០០ ។

៥. លើសពីនេះទៀត លក្ខណៈនៃរបៀបដែលការជំទាស់របស់ដើមបណ្តឹងសាទុក្ខដែលបានលើកឡើងពីយុត្តាធិការបុគ្គល គឺនៅថ្ងៃចុងក្រោយនៃការជំនុំជម្រះជាងប្រាំបួន(៩)ខែ នៅក្រោយពេលដែលភាគីនានាបានធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ជាលាយលក្ខអក្សររបស់ខ្លួន និងនៅក្រោយការបដិសេធយ៉ាងច្បាស់លាស់ពីមុនរបស់ដើមបណ្តឹងសាទុក្ខ នូវចេតនាណាមួយក្នុងការជំទាស់នឹងយុត្តាធិការបុគ្គល គឺបានបង្ហាញពីការគ្មានចិត្តសុចរិតរបស់ដើមបណ្តឹងសាទុក្ខនៅក្នុងការដោះស្រាយបញ្ហាជាមួយនឹង អវតក។ ស្រដៀងគ្នានេះដែរ ការអះអាងរបស់គាត់ដែលថាអង្គជំនុំជម្រះតុលាការកំពូលគួរត្រូវដោះលែងរូបគាត់ ទោះបីជាសម្បទានរបស់គាត់ដែលថាគាត់មានពិរុទ្ធភាពដោយអំពើសាហាវយង់ឃ្នងដ៏រង្គាល បង្ហាញពីភាពមិនស្មោះសនៃការប្រកាសពីវិប្បដិសារីរបស់ខ្លួន។ ដូចដែលសហព្រះរាជអាជ្ញាបានលើសំអាងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ទៅលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ (“សាលក្រម”) ដូច្នោះដែរ គេគួរតែយកចិត្តទុកដាក់ទៅលើបញ្ហានៃការគ្មានចិត្តសុចរិត និងភាពស្មោះស ខណៈដែលអង្គជំនុំជម្រះតុលាការកំពូលពិចារណាពីភាពគ្រប់គ្រាន់នៃការផ្តន្ទាទោសដែលបានដាក់ទៅលើដើមបណ្តឹងសាទុក្ខ[6]។

៦. សហព្រះរាជអាជ្ញានឹងលើកពីអង្គសេចក្តីនៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះ នៅខាងក្រោមដោយចាប់ផ្តើមពីផ្នែកទីII ។ ទោះជាដូច្នេះក៏ដោយ ក៏សហព្រះរាជអាជ្ញា ជាបញ្ហាដំបូង ព្យាយាមលើកឡើងនូវបញ្ហាស្តីពីកង្វល់ដែលជាប់ទាក់ទងនឹងភាពអាចទទួលយកបាននូវសារណានេះ ដែលបានធ្វើឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។

[6] សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌទី ៦៣, ៧៧ ។

៧. ជាពិសេស បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះមិនបានឆ្លុះបញ្ចាំងនូវបទដ្ឋានអប្បបរមានៃញត្តិដែលគេតម្រូវ បើមិនទាំងអស់ទេ ឲ្យមានសេចក្តីសំអាងជាច្រើន ដូចដែលមាននៅក្នុងទីនេះ[7]។ វិធាន១០៥ បានចែងថា បណ្តឹងសាទុក្ខត្រូវមានចែងពីសេចក្តីសំអាង និងប្រភពអង្គច្បាប់ដែលគាំទ្រដល់ទទ្បីករណ៍នីមួយៗ ហើយមូលដ្ឋាន ឬខ្លឹមសារនៃសេចក្តីសម្រេច ដែលត្រូវបានជំទាស់ដោយដើមបណ្តឹងសាទុក្ខត្រូវតែមានបញ្ជាក់ "ដោយលេខយោងទំព័រ និងលេខ វាក្យខណ្ឌជាក់លាក់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង"[8]។ ស្រដៀងគ្នានេះដែរ វាគឺជាគោលការណ៍មួយដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តជាអន្តរជាតិ ដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានលើកសំអាងរួចមកហើយ គឺមានការពាក់ព័ន្ធនៅត្រង់នេះ[9] ដែលថាសារណាបណ្តឹង

---

[7] ដោយមានការពាក់ព័ន្ធគ្នា ពីព្រោះសំអាងហេតុរបស់ដើមបណ្តឹងសាទុក្ខនៅពេលនោះមិនត្រូវបានបញ្ជាក់ឲ្យបានច្បាស់ៗទេ ។ មានការពិបាកនៅក្នុងការវាយតម្លៃថាតើសារណាដែលបានធ្វើជាបណ្តឹងសាទុក្ខនោះ ឋិតនៅក្នុងវិសាលភាពនៃទទ្បីករណ៍នៅក្នុងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ ឬយ៉ាងណា ។ ឧទាហរណ៍ មិនមានភាពច្បាស់លាស់ទេថាតើបញ្ហាភស្តុតាងដែលបានលើកឡើងនៅក្នុងទទ្បីករណ៍ទី២ នៃបណ្តឹង សាទុក្ខត្រូវបានយោងយ៉ាងសមហេតុសមផលនៅក្នុងសេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ ឬយ៉ាងណានោះទេ ដែលបានដាក់ចំណងជើងថា៖ "ការភាន់ច្រឡំចំពោះការផ្តន្ទាទោសដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ ឆ្នាំ" ។ *សូមមើល* សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៤ សីហា ២០១០, E188/8 [បន្ទាប់ពីនេះទៅហៅថា៖ "សេចក្តីជូនដំណឹងរបស់សហមេធាវីការពារក្តីអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម"], ទទ្បីករណ៍ទី២ (ចំណងជើង) ។ ដោយអនុលោមតាមវិធាន ១១០ សហព្រះរាជអាជ្ញាកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលគួរកុំយកចិត្តទុកដាក់នឹងការវិវត្តន៍នៃបញ្ហាណាមួយនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ដែលមិនមាននៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដំបូង ។ *សូមមើល* វិធានផ្ទៃក្នុងសម្រាប់ អវតក (វិសោធនកម្មលើកទី ៦), ថ្ងៃទី១៧ កញ្ញា ២០១០ [បន្ទាប់ពីនេះទៅហៅថា៖ "វិធានផ្ទៃក្នុង"], វិធាន ១១០ ("វិសាលភាពនៃបណ្តឹងសាទុក្ខ ត្រូវកម្រិតត្រឹមបញ្ហា ដែលលើកឡើងក្នុងលិខិតប្តឹងសាទុក្ខ និងតាមលក្ខណៈសម្បត្តិរបស់អ្នកប្តឹងសាទុក្ខ") ។

[8] វិធានផ្ទៃក្នុង, វិធាន ១០៥ ។

[9] ដូចដែលសហព្រះរាជអាជ្ញា បានពន្យល់រួចហើយនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួនថា យុត្តាធិការនៃតុលាការ ICTY និង ICTR អាចផ្តល់នូវគោលការណ៍ណែនាំដល់អង្គជំនុំជម្រះតុលាការកំពូលបាន នៅក្នុងការវិនិច្ឆ័យលើបណ្តឹងសាទុក្ខនៅ អវតក ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌទី ១៨ (ដោយមានការពន្យល់ថា វិធានផ្ទៃក្នុងសម្រាប់ អវតក ពាក់ព័ន្ធនឹងការពិនិត្យបណ្តឹងសាទុក្ខមានចេតនាយកចេញមកពីការអនុវត្តតាមបែបនៅក្នុងប្រទេសកម្ពុជាស្តីពីការពិនិត្យសារជាថ្មីឡើងវិញ តែបែរជាបានយកលំនាំភាសាតាមតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលផ្តល់នូវទម្រង់នៃការពិនិត្យសារឡើងវិញមួយដែលមានកំរិតជាង) ។ *សូមមើលផងដែរ* ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី [បន្ទាប់ពីនេះទៅហៅថា៖ "ច្បាប់លក្ខន្តិកៈនៃតុលាការ ICTY"], ថ្ងៃទី២៥ ឧសភា ១៩៩៣, វិសោធនកម្មថ្ងៃទី៧ កក្កដា ២០០៩, មាត្រា ២៥ ។ ច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់

សាទុក្ខត្រូវតែគាំទ្រដល់ទឡ្ហីករណ៍នានា ចំពោះបណ្តឹងសាទុក្ខមួយដែលមានយោងយ៉ាងជាក់លាក់ទៅលើ៖ ទី១) ទំព័រប្រតិចារិកដែលពាក់ពន្ធ័ ឬវាក្យខណ្ឌដែលខ្លួនជំទាស់ និងទី២) ផ្នែកផ្សេងៗនៃកំណត់ត្រាដែលត្រូវបានសំអាងលើមានការគាំទ្រដល់ការជំទាស់របស់ខ្លួន[10]។ បើដើមបណ្តឹងសាទុក្ខគ្រាន់តែធ្វើការយោងជាទូទៅនៅក្នុងការដាក់ញត្តិ [ប្រឆាំងនឹងសាលក្រម]ជំនុំជម្រះ ឬបើមិនដូច្នោះទេ ខកខានមិនបានបញ្ជាក់ពីខ្លឹមសារនៃសេចក្តីសំអាងនានារបស់ខ្លួន ដោយការមិនបានផ្តល់នូវសេចក្តីយោងជាក់លាក់ដោយប្រតិចារិក កំណត់ហេតុ ឬសាលក្រមទេនោះ អង្គជំនុំជម្រះតុលាការកំពូលអាចនឹងមិនធ្វើការពិចារណាទៅលើសេចក្តីសំអាងបែបនោះឡើយ[11]។ លើសពីនេះទៀត អង្គជំនុំជម្រះតុលាការកំពូល "មិនត្រូវបានគេរំពឹងថានឹងពិចាណាលំអិតលើញត្តិនានារបស់

ប្រទេសរ៉្វាន់ដា [បន្ទាប់ពីនេះទៅហៅថា៖ "ច្បាប់លក្ខន្តិកៈនៃតុលាការ ICTR"], ថ្ងៃទី៨ វិច្ឆិកា ១៩៩៤, វិសោធនកម្មថ្ងៃទី៣១ មករា ២០១០, មាត្រា ២៤ ។

10 *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង* Ntakirutimana, សាលដីកា, ICTR-96-10-A និង ICTR-96-17-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR, ថ្ងៃទី១៣ ធ្នូ ២០០៤, កថាខណ្ឌទី ៣៩៦ ("អវត្តមាននៃឯកសារយោងជាក់លាក់ នោះគេមិនអាចរំពឹងបានទេថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងពិចារណាលើសារណាមួយដែលបានដាក់") ។ *រដ្ឋអាជ្ញា ទល់នឹង Kordić,* សាលដីកា, IT-95-14/2-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី១៧ ធ្នូ ២០០៤, កថាខណ្ឌទី ២៣ ("ភាគីនានាត្រូវតែផ្តល់ជូនដល់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នូវឯកសារយោងចំៗទៅនឹងផ្នែកផ្សេងៗនៃកំណត់ត្រាបណ្តឹងឧទ្ធរណ៍(សាទុក្ខ)ដែលសំអាងលើការគាំទ្ររបស់វា ។ គេក៏ត្រូវតែផ្តល់ដល់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ផងដែរនូវឯកសារយោងនានាមានវត្ថុតាង ឬប្រភពច្បាប់នានា ដោយមានការបញ្ជាក់ចំៗពីកាលបរិច្ឆេទ និងលេខទំព័រឯកសារ ឬលេខកថាខណ្ឌនៃអត្ថបទដែលគេបានយោងនោះ") ។ *រដ្ឋអាជ្ញា ទល់នឹង* Nahimana, សាលដីកា, ICTR-99-52-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR, ថ្ងៃទី២៨ វិច្ឆិកា ២០០៧ [បន្ទាប់ពីនេះទៅហៅថា៖ "សាលដីកាលើករណីរបស់ *Nahimana*"], កថាខណ្ឌទី ៥១១ ("ដើមបណ្តឹងឧទ្ធរណ៍(សាទុក្ខ)ណា ដែលខានបញ្ជាក់ពីឯកសារយោង ជាក់លាក់ទៅនឹងប្រតិចារិកដែលបានពោលនៅក្នុងច្បាប់នេះ បើដូច្នោះគឺមិនបានធ្វើត្រូវទៅតាមលក្ខខណ្ឌតម្រូវនានាសម្រាប់ធ្វើឲ្យសារណានោះ បានទៅដល់ដំណាក់កាលឧទ្ធរណ៍(សាទុក្ខ)ឡើយ") ។

11 *សូមមើល, ឧទា. រដ្ឋអាជ្ញា ទល់នឹង Kvočka,* សាលដីកា, IT-98-30/1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី២៨ កុម្ភៈ ២០០៥ [បន្ទាប់ពីនេះទៅហៅថា៖ "សាលដីកាលើករណីរបស់ *Kvočka*], កថាខណ្ឌទី ៤២៥ (លើកឡើងថា "ឯកសារយោងទូទៅភ្ជាប់ទៅនឹងសារណាដែលបានធ្វើឡើងក្នុងអំឡុងពេលនៃសវនាការ ពិតជាមិនបានបំពេញនូវលក្ខខណ្ឌតម្រូវដើម្បីលើកឡើងឲ្យមានតម្លាភាពអំពីទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍និងសំអាងហេតុនានាដែលគាំទ្រវាទេ] ។ ហេតុដូច្នេះ នឹងមិនត្រូវបានអង្គជំនុំជម្រះសាលាឧទ្ធរណ៍ យកចិត្តទុកដាក់ទេ") ។

ភាគីណាមួយទេ បើញត្តិទាំងនោះមិនច្បាស់លាស់ ផ្ទុយគ្នា ស្រពិចស្រពិល ឬទទួលរងនូវភាព មិនគ្រប់គ្រាន់ដទៃទៀតតាមទម្រង់ការ និងដោយជាក់ស្តែង[12]។

៨. ដោយល្មើសនឹងបទដ្ឋានដូចដែលបានលើកឡើងខាងលើជាដដែលៗ ដើមបណ្តឹងសាទុក្ខនៅតែ៖(១) ខកខានមិនគាំទ្រចំពោះទឡ្ហីករណ៍របស់ខ្លួន ដោយ(មិនបាន)យោងជាក់លាក់ទៅលើកំណត់ហេតុ ប្រតិចារិក ភស្តុតាង ឬសាលក្រមនោះទេ[13]។ (២) ធ្វើឱ្យមានភាពមិនច្បាស់លាស់ ផ្ទុយគ្នា ស្រពិចស្រពិល ឬ គ្មានសំអាងគ្រប់គ្រាន់[14]។ (៣) តិទៀនចំពោះការទាញហេតុផលរបស់អង្គជំនុំ

---

[12] *រដ្ឋអាជ្ញា ទល់នឹង Galić*, សាលដីកា, IT-98-29-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី៣០ វិច្ឆិកា ២០០៦, កថាខណ្ឌទី ១១ ។ *សូមមើលផងដែរ, រដ្ឋអាជ្ញា ទល់នឹង Muvunyi*, សាលដីកា, ICTR-2000-55A-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR, ថ្ងៃទី២៩ សីហា ២០០៨ [បន្ទាប់ពីនេះទៅហៅថា៖ "សាលដីកាលើករណីរបស់ *Muvunyi*], កថាខណ្ឌទី ១២ (លើកឡើងថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ "នឹងបដិសេធចោលនូវសំអាងហេតុណាដែលមិនមានមូលដ្ឋានជាក់ស្តែង ដោយមិនបានផ្តល់នូវការបង្ហាញហេតុផលលំអិត") ។ *រដ្ឋអាជ្ញា ទល់នឹង Vasiljević*, សាលដីកា, IT-98-32-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ថ្ងៃទី២៥ កុម្ភៈ ២០០៤, កថាខណ្ឌទី ១២ (លើកឡើងថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍អាចនឹងបដិសេធចោលទាំងស្រុងនូវ សំអាងហេតុទាំងឡាយណាដែលដើមបណ្តឹងឧទ្ធរណ៍គ្រាន់តែស្នើសុំឱ្យធ្វើការវាយតម្លៃផ្សេងទៀតលើភស្តុតាងនោះ ដោយមិនបានបញ្ជាក់ថាតើអំពីបញ្ហាមួយណាដែលការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើភស្តុតាងនោះ មានការភាន់ច្រឡំ) ។

[13] *សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កថាខណ្ឌទី៤-៦ (ដែលលើកឡើងជាទូទៅ ដោយមិនមានការយោង ឬលើកសំអាងជាក់លាក់, ដល់ "ភស្តុតាងគាំទ្រ" ឬដល់ "ភស្តុតាងដោះបន្ទុក"ដែលបានលើកឡើងចោទប្រកាន់ដោយដើមបណ្តឹងសាទុក្ខនៅក្នុងពេលដំណើរការនីតិវិធី)។ កថាខណ្ឌទី២១ (បានតវ៉ាជំទាស់ថា យុត្តាធិការបុគ្គល គឺផ្អែកជាសំខាន់ទៅលើមូលដ្ឋាននៃបទដ្ឋានរដ្ឋបាលរបស់ជាតិដោយពុំបានផ្តល់សេចក្តីយោងទៅលើបទដ្ឋានទាំងនោះឡើយ)។ កថាខណ្ឌទី២២ (លើកឡើងជាទូទៅសំដៅលើ " បទដ្ឋានគតិយុត្តិសំខាន់ៗនានារបស់ជាតិ") ដែលបញ្ជាក់ថា ដើមបណ្តឹងសាទុក្ខមិនត្រូវបានគេចាត់ចូលនៅក្នុងរចនាសម្ព័ន្ធនៃ "មេដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយមិនបានយោងដោយត្រឹមត្រូវទៅលើបទដ្ឋានទាំងនោះឡើយ)។ កថាខណ្ឌទី២៥ (ដែលលើកឡើងជាទូទៅសំដៅទៅលើ "ទ្រឹស្តីនៃច្បាប់មួយដែលកំណត់និយមន័យអំពីអ្នកទទួលខុសត្រូវខ្ពស់បំផុត) ដែលមិនបានថែងច្បាស់លាស់ ដែលតាមទ្រឹស្តីនោះគឺឱ្យនិយមន័យជននោះដោយពិនិត្យមើលទៅលើអំណាចឆន្ទៈរបស់ពួកគេនៅក្នុងឋានានុក្រមនិងទៅលើឆន្ទៈក្នុងការសម្រេចជ្រើសរើសរបស់ពួកគេ ដោយធ្វើការប្រៀបធៀបទៅនឹងលេខាដទៃៗទៀតនៃពន្ធនាគារ)។ កថាខណ្ឌទី៤៦-៥០ (តវ៉ាទាមទារដោយមិនបានយោង ឬលើកសំអាងជាក់លាក់ទៅលើសក្ខីកម្មរបស់សាក្សី ឬភស្តុតាងផ្សេងទៀត ដែលថាមានមនុស្សមួយក្រុមចំនួនដប់នាក់បានធ្វើការវាយប្រហារនៅទីក្រុងភ្នំពេញនិងបាត់ដំបងនិងដែលក្រោយមកទៀតបានអនុវត្តនូវផែនការឧក្រិដ្ឋកម្មរបស់ពួកគេ ) ។ កថាខណ្ឌទី៩០ (ដែលជាទូទៅលើកឡើង ដោយមិនបានយោង ឬលើកសំអាងជាក់លាក់ទៅលើ" ភស្តុតាង" ដែលចោទប្រកាន់ដែលបង្ហាញថា ឌុច គ្មានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចនានាដោយឯកឯងនោះទេ)។

[14] *សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់មេធាវី កថាខណ្ឌទី១៩, ៦០-៦២ (ដែលតវ៉ាដោយមិនមានភាពស៊ីសង្វាក់គ្នាថាអង្គជំនុំជម្រះសាលាដំបូងមិនត្រូវរកមើលអ្វីក្រៅពីច្បាប់ អវតក សម្រាប់ធ្វើជាសេចក្តីណែនាំនៅក្នុងការកំណត់អំពីយុត្តាធិការបន្ទាប់ពីលើកសំអាងកាលពីមុនទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀត នោះទេ)។ កថាខណ្ឌទី២៣ , ២៥ (ដែលពោលអះអាងដោយងងឹត

ជម្រះសាលាដំបូងដោយមិនបានផ្តល់នូវការចង្អុលភស្តុតាងឬសំអាងអំពីកំហុសឆ្គងដែលចោទប្រកាន់ថាបានប្រព្រឹត្តនោះឡើយ[15]។ និង (៤) ការលើកឡើងខុស ហើយការកំណត់បទចោទខុសគ្នាពីអង្គហេតុ និងអង្គច្បាប់ ដើម្បីគាំទ្រចំពោះទឡ្ហីករណ៍នានារបស់ខ្លួន[16]។ ភាពខ្វះខាតមួយចំនួន

---

ងងល់ថា ពីព្រោះពន្ធនាគារដទៃៗទៀតត្រូវបានគេអះអាងឲ្យដឹងថាមានជនរងគ្រោះចំនួនច្រើនលើសពីមន្ទីរស-២១ទៅទៀត) ដែលនេះគឺជា "ការបញ្ជាក់យ៉ាងច្បាស់ ) ថា អតីតប្រធានៗនៃពន្ធនាគារគឺមិនត្រូវបានគេចាត់ទុកថាជាអ្នកដែលទទួកខុសត្រូវខ្ពស់បំផុតនោះទេ )។ កថាខណ្ឌទី៣០ (បានលើកឡើងតវ៉ាដោយងងឹតងងល់ថា ដើមបណ្តឹងសាទុក្ខមិនបានដឹងពីសេចក្តីណែនាំពិសេសណាមួយទេ គាត់មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់ជាងគេបំផុតនោះទេ។ កថាខណ្ឌទី៩៣ (និយាយ ដោយមិនបានលើកសំអាងដើម្បីគាំទ្រ ឬមកពន្យល់បន្ថែមទៀតនោះ ថាដើមបណ្តឹងសាទុក្ខមិនអាចមានលទ្ធភាពក្នុងការបង្ហាញនូវភស្តុតាងដោះបន្ទុកបានភ្លាមៗទេ ពីព្រោះសហព្រះរាជអាជ្ញាខកខានមិនបានធ្វើការស៊ើបអង្កេតទៅលើមេដឹកនាំជាន់ខ្ពស់នានានិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនានានៅមន្ទីរស-២១ ដែលនាំឲ្យសហព្រះរាជអាជ្ញាជឿថាដើមបណ្តឹងសាទុក្ខគឺស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មទាំងនេះ)។ កថាខណ្ឌទី ១៤-១៥ (ខកខានមិនបានពន្យល់ថាតើអាចដឹងថាអង្គជំនុំជម្រះសាលាដំបូងមិនបានពិនិត្យទៅលើរដ្ឋធម្មនុញ្ញកម្ពុជានិងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជា
ប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់នោះតើដឹងតាមរបៀបយ៉ាងដូចម្តេច? ឬតើការពោលអះអាងអំពីការខកខានមិនបានពិនិត្យមើលរបស់អាជ្ញាធរទាំងនោះបានបណ្តាលឲ្យសាលក្រមអសុពលភាពនោះតើបណ្តាលតាមបែបដូចម្តេច?នោះទេ )។

[15] *សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់មេធាវី កថាខណ្ឌទី៦៩ (ដែលពោលអះអាងថា អង្គជំនុំជម្រះសាលាដំបូង "*បានប្រើការសន្មត់ច្រើនពេក* ដោយនិយាយថា ខ្លួនយល់ស្របតាមព្រះរាជអាជ្ញា " (សង្កត់ន័យដោយអក្សរទ្រេត) ។ កថាខណ្ឌទី២៥( និយាយថា *អង្គជំនុំជម្រះសាលាដំបូងបានយល់ស្រប ដោយមិនបានវែកញែកហេតុផលឲ្យបានសមហេតុសមផលដោយមិនបានលើកសំអាងទៅលើអង្គច្បាប់ឲ្យបានសមស្រប គឺជាការមិនមិនត្រឹមត្រូវ* ដែលអយ្យការបានផ្អែកលើមូលដ្ឋាននេះដើម្បីជំរុញឲ្យធ្វើការចោទប្រកាន់លើជនជាប់ចោទ[...] *ការលើកសំអាងទាំងនេះមិនមានភាពតក្កវិជ្ជា (ឡូហ្សិក) តាមផ្លូវច្បាប់ទេ* ហើយមិនអាចយកមកប្រើដើម្បីកំណត់ឋានៈរបស់ជនណាម្នាក់ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតបានទេ") (សង្កត់ន័យដោយអក្សរទ្រេត)។ កថាខណ្ឌទី១៥ (ពោលអះអាងថាអង្គជំនុំជម្រះសាលាដំបូងបានខកខានមិនបានយកចិត្តទុកដាក់ទៅលើច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់) ក្នុងការពិនិត្យពិចារណាអំពីយុត្តាធិការបុគ្គលរបស់ខ្លួនទៅលើដើមបណ្តឹងសាទុក្ខដោយគ្មានការផ្តល់នូវសំអាងឬការពន្យល់ណាមួយអំពីថាតើ ច្បាប់នេះត្រូវបានគេយកមកអនុវត្តចំពោះដើមបណ្តឹងសាទុក្ខ ឬឧក្រិដ្ឋកម្មផ្សេងៗរបស់គាត់តាមរបៀបដូចម្តេចឡើយ)។

[16] *សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់មេធាវី កថាខណ្ឌទី៣.៣ (ដែលតវ៉ាថា ឯកសារនានាដែលបង្កើត អវតក បានកំរិតដែនយុត្តាធិការរបស់ អវតក ឲ្យនៅត្រឹមតែទៅលើឧក្រិដ្ឋម្មទាំងឡាយដែលប្រព្រឹត្តនៅក្នុងទឹកដីកម្ពុជាប៉ុណ្ណោះ ដែលឯកសារទាំងនោះកំរិតតែទៅលើយុត្តាធិការពេលវេលា និងទៅលើកម្មវត្ថុរឿងក្តីតែប៉ុណ្ណោះ មិនបានមិនកំរិតលើភូមិសាស្ត្រនោះឡើយ)។ កថាខណ្ឌទី២៦ (ដែលលើកឡើងដោយមិនត្រឹមត្រូវថា អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីការចោទប្រកាន់ថាដើមបណ្តឹងឧទ្ធរណ៍បានចូលរួមនៅក្នុងការរៀបចំផែនការក្នុងការបង្កើតមន្ទីរស-២១)។ កថាខណ្ឌទី៩១, ៩៩ (ដែលបានបកស្រាយដោយខុសថា ប្រការដែលមានចៅក្រមអង្គជំនុំជម្រះសាលាដំបូងមួយរូបបានជំទាស់អំពីបរិមាណនៃការផ្តន្ទាទោស ដោយថាមានន័យថាមាន "ភាពមិនប្រក្រតីនៅក្នុងការផ្តល់យុត្តិធម៌ដល់ជនជាប់ចោទ "ទៅវិញ) ។ ផ្ទុយទៅវិញ មាត្រា១៤.ក នៃកិច្ចព្រមព្រៀងស្តីពី អវតក និងវិធាន៩៨.៤ គ្រាន់តែតម្រូវឲ្យមានសម្លេងឆ្នោតគាំទ្រដោយចៅក្រមចំនួនបួនរូបយ៉ាងតិចតែប៉ុណ្ណោះ ដែលធ្វើបានសម្រេច)។

ក្នុងចំណោមការខ្វះខាតដែលលេចឡើងច្បាស់ជាងគេបំផុត និង/ឬ ភាពមិនត្រឹមត្រូវនៅក្នុងបណ្តឹងសាទុក្ខរួមមានដូចខាងក្រោមនេះ៖

- ដើមបណ្តឹងសាទុក្ខលើកឡើងម្តងហើយម្តងទៀតដដែលៗ អំពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបានពិចារណាទៅលើ "សេចក្តីសន្និដ្ឋាន" របស់ខ្លួនស្តីពីយុត្តាធិការបុគ្គល" តែដោយមិនបានធ្វើការបញ្ជាក់ច្បាស់អំពីថាតើចង់សំដៅទៅលើសេចក្តីសន្និដ្ឋានណាមួយ ឬនិយាយឱ្យបានច្បាស់ថាតើសេចក្តីសន្និដ្ឋានទាំងនោះ ត្រូវបានធ្វើឡើងពីពេលណានោះទេ ទោះបីជាជាក់ស្តែងទាំងអស់នេះសុទ្ធតែជាអង្គហេតុជាគន្លឹះយ៉ាងណាក៏ដោយ[17]។
- ដើមបណ្តឹងសាទុក្ខបានពោលអះអាងដោយខុសថា យោបល់ជំទាស់របស់លោកចៅក្រម Lavergne "បានទទួលស្គាល់[]"ថា អង្គជំនុំជម្រះសាលាដំបូងគ្មានយុត្តាធិការទៅលើដើមបណ្តឹងសាទុក្ខទេ[18]។ ផ្ទុយទៅវិញ យោបល់ជំទាស់នេះ គឺត្រូវបានកំរិតត្រឹមតែការពិភាក្សាពីទំហំនៃទោសដែលផ្តន្ទាទោសចំពោះដើមបណ្តឹងសាទុក្ខតែប៉ុណ្ណោះ[19]។
- ដើមបណ្តឹងសាទុក្ខតវ៉ាថាច្បាប់ អវតក មិនអនុញ្ញាតឱ្យចោទប្រកាន់លើជនណាម្នាក់ដែលបានធ្វើសកម្មភាពតាមបញ្ជាគេនៅក្នុងការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មផ្សេងៗដែលខ្លួនត្រូវបានកាត់ឱ្យមានទោសតែប៉ុណ្ណោះ[20]។ ក៏ប៉ុន្តែច្បាប់ អវតក បានចែងយ៉ាងច្បាស់ផ្ទុយពីនេះទៅវិញ។ ជាពិសេស មាត្រា២៩នៃច្បាប់ អវតក ចែងថា " ប្រការដែលថាជនសង្ស័យបាន

---

[17] *សូមអាន ឧទាហរណ៍ដូចជា* សារណាបណ្តឹងសាទុក្ខរបស់មេធាវី កថាខណ្ឌទី៤-៥, ទី៦៦-៧១។

[18] សារណាបណ្តឹងសាទុក្ខរបស់មេធាវី, កថាខណ្ឌទី៩៦។

[19] យោបល់ដាច់ដោយឡែក និងជំទាស់ របស់លោកចៅក្រម Jean-Marc Lavergne ស្តីពីការផ្តន្ទាទោស, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី២៦ កក្កដា ២០១០, ឯកសារលេខ E188.1។

[20] សារណាបណ្តឹងសាទុក្ខរបស់មេធាវី , កថាខណ្ឌទី ៣៧-៣៨។

ប្រព្រឹត្តអំពើឧក្រិដ្ឋទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឱ្យរួចផុតពីការទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋនេះបានឡើយ”[21]។

- ដើមបណ្តឹងសាទុក្ខនិយាយអះអាងថា មាត្រា២៩០.៦នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគាំទ្រចំពោះទឡ្ហីករណ៍របស់ខ្លួនទាក់ទងនឹងការមិនមានយុត្តាធិការបុគ្គលរបស់ អវតក ទោះបីជាមាត្រា២៩០.៦នេះ បានចែងច្បាស់អំពីយុត្តាធិការដែនដី មិនមែនអំពីយុត្តាធិការបុគ្គលទេ[22]។

៩. សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា ស្របតាមយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ទឡ្ហីករណ៍របស់ដើមបណ្តឹងសាទុក្ខដែលភស្តុតាងមិនមានមូលដ្ឋានត្រឹមត្រូវ ឬនិយាយម្យ៉ាងទៀតថា ខកខានមិនបានបំពេញគ្រប់តាមលក្ខខណ្ឌតម្រូវអប្បបរមា ក្នុងការផ្តល់សំអាងនោះ អង្គជំនុំជម្រះតុលាការកំពូលគួរតែបដិសេធកុំយកជាការ។ ការខកខានរបស់ដើមបណ្តឹងសាទុក្ខក្នុងការប្រតិបត្តិតាមលក្ខខណ្ឌតម្រូវជាមូលដ្ឋានទាំងនេះ គឺជាការដាក់បន្ទុកដោយមិនត្រឹមត្រូវទៅលើភាគីនានា និងទៅលើអង្គជំនុំជម្រះតុលាការកំពូល ដើម្បីឱ្យធ្វើការស៊ើបអង្កេត ចង្អុលបង្ហាញភស្តុតាង និងរចនាសម្ព័ន្ធនៃទឡ្ហីករណ៍របស់ដើមបណ្តឹងសាទុក្ខឱ្យខ្លួន និងគ្រប់ពេលវេលាទាំងអស់តម្រូវឱ្យមានការប៉ាន់ស្មានអំពីខ្លឹមសារនៃអំណះអំណាងនោះ។ នេះគឺជាការមិនស្របទៅនឹងការចាំបាច់ក្នុងការជួយលើកស្ទួយដល់ការសន្សំសំចៃរបស់តុលាការ និងនីតិវិធីនៅ អវតកឡើយ។

---

[21] ច្បាប់ អវតក, មាត្រា២៩ ដែលបានចែងផងដែរថា “តួនាទីឬឋានៈ” របស់ជនជាប់ចោទណាម្នាក់មិនអាចជួយជននេះឱ្យរួចផុតពីការទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋ ឬជួយបន្ថយទោសដល់ជននេះបានឡើយ។

[22] *សូមអាន* សារណាបណ្តឹងសាទុក្ខរបស់មេធាវី, កថាខណ្ឌទី៧០។

១០. យ៉ាងនេះក្តី ទោះបីជាគ្មានភាពច្បាស់លាស់ និងជាក់លាក់នៅក្នុងបណ្តឹងសាទុក្ខនោះក៏ដោយ ក៏សហព្រះរាជអាជ្ញាបានប៉ុនប៉ងនឹងលើកឡើងអំពីចំណុចគោលធំៗរបស់ដើមបណ្តឹងសាទុក្ខនៅក្នុងចម្លើយតបនេះដែរ។ សហព្រះរាជអាជ្ញា មិនបោះបង់ចោលនូវសិទ្ធិរបស់ខ្លួនក្នុងការដាក់បំពេញបន្ថែមនូវសេចក្តីសន្និដ្ឋានរបស់ខ្លួននៅពេលណាមួយក្រោយទៀត នៅក្នុងពេលរង់ចាំការបញ្ជាក់បំភ្លឺ ឬការចង្អុលបង្ហាញភស្តុតាងពីខាងដើមបណ្តឹងសាទុក្ខនោះទេ។

## ២. ចម្លើយតបទៅនឹងទឡ្ហីករណ៍ទី១៖ អង្គជំនុំជម្រះសាលាដំបូងមិនបានភាន់ច្រឡំអំពី "យុត្តាធិការបុគ្គល" នោះឡើយ

១១. ជាទឡ្ហីករណ៍ទី១នៃបណ្តឹងសាទុក្ខ សហមេធាវីការពារក្តីចោទប្រកាន់ថា "អង្គជំនុំជម្រះសាលាដំបូងបានភាន់ច្រឡំទាក់ទងអំពីយុត្តាធិការបុគ្គល"[23]។ ជាការឆ្លើយតបវិញ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា (១)អង្គជំនុំជម្រះសាលាដំបូងមិនបានភាន់ច្រឡំទេក្នុងការរកឃើញថាការជំទាស់របស់ដើមបណ្តឹងសាទុក្ខអំពីយុត្តាធិការបុគ្គលគឺបានធ្វើឡើងដោយមិនចំពេលវេលា អាស្រ័យហេតុនេះមិនអាចឲ្យទទួលយកបានឡើយ។ (២) ផ្ទុយទៅវិញ ទឡ្ហីករណ៍ទី១នៃបណ្តឹងសាទុក្ខត្រូវបរាជ័យពីព្រោះអង្គជំនុំជម្រះសាលាដំបូងមិនបានភាន់ច្រឡំឡើយ នៅក្នុងការបញ្ជាក់ថាយុត្តាធិការបុគ្គលរបស់ខ្លួនទៅលើដើមបណ្តឹងសាទុក្ខដោយផ្អែកលើមូលដ្ឋាននៃឋានៈរបស់គាត់ដែលជាអ្នកទទួលខុសត្រូវម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។

---

[23] សារណាបណ្តឹងសាទុក្ខរបស់មេធាវី, កថាខណ្ឌទី១១។

## ក. អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងការសម្រេចថាការជំទាស់អំពីយុត្តាធិការបុគ្គលរបស់ដើមបណ្តឹងសាទុក្ខ ធ្វើឡើងមិនចំពេលវេលា និងថាបើដូច្នេះមិនអាចទទួលយកបាន

១២. អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការជំទាស់របស់ដើមបណ្តឹងសាទុក្ខអំពីការអនុវត្តយុត្តាធិការបុគ្គលមកលើរូបគាត់ ដែលត្រូវបានបង្ហាញនៅថ្ងៃចុងក្រោយនៃសវនាការ ដែលមានរយៈពេលប្រាំបួនខែ គឺ "យឺតពេលហើយ" និងថាហេតុដូច្នេះ មិនអាចទទួលយកបានទេ ដោយអនុលោមតាមវិធាន៨៩[24]។ បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី តវ៉ាចំពោះការសម្រេចនេះ ដោយចោទថា អង្គជំនុំជម្រះសាលាដំបូង "បានអនុវត្តវិធាន៨៩ នៅក្នុងពេលវេលាដែលខុស និងដែលមានវិការៈខាងផ្នែកនីតិវិធី"[25]។

### i. បទដ្ឋាននៃការត្រួតពិនិត្យ

១៣. វិធាន១០៤.១ នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះតុលាការកំពូល មានសមត្ថកិច្ច ដើម្បីពិចារណាទៅលើការចោទប្រកាន់ចំពោះ "ការភាន់ច្រឡំណាមួយអំពីបញ្ហាច្បាប់ ដែលធ្វើឱ្យអស់សុពលភាពចំពោះសាលក្រម ឬសេចក្តីសម្រេច"[26]។ នៅពេលពិនិត្យអំពីការភាន់ច្រឡំផ្នែកច្បាប់តាមដែលគេបានចោទប្រកាន់ អង្គជំនុំជម្រះតុលាការកំពូល ICTY និង ICTR ដែលជាតុលាការអនុវត្តបទដ្ឋានដូចគ្នាក្នុងការពិនិត្យបណ្តឹងសាទុក្ខ ដូចមានចែងក្នុងវិធាន១០៤ដែរនោះ មិនបានរារាំងខ្លួនឯងមិន

---

[24] សាលក្រម, សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ២៦ កក្កដា ២០១០, E188, ["ចាប់ពីនេះតទៅហៅថា សាលក្រមសំណុំរឿងលេខ ០០១"], កថាខណ្ឌទី១៤-១៥ ។

[25] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី៧១ ។

[26] វិធាន១០៤.១ នៃវិធានផ្ទៃក្នុង ។

ឱ្យធ្វើការវាយតម្លៃទៅលើភាពសមហេតុសមផលនៃការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងទេ។ ដូច្នេះ គេបង្កើតឱ្យមានការវាយតម្លៃឯករាជ្យមួយថាតើ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង គឺជាការត្រឹមត្រូវ ឬទេអំពីបញ្ហាច្បាប់[27]។ យោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដដែលនេះ គឺថាភាគីមួយដែលចោទប្រកាន់ថាមានការភាន់ច្រឡំផ្នែកច្បាប់ ធ្វើឱ្យអស់សុពលភាពនៃសាលក្រម យ៉ាងហោចបំផុត ក៏ត្រូវបង្ហាញអត្តសញ្ញាណអំពីការភាន់ច្រឡំនោះ អំពីអំណះអំណាងគាំទ្រចំពោះការអះអាងរបស់ខ្លួន និងពន្យល់ថាតើ ការភាន់ច្រឡំនោះធ្វើឱ្យអស់សុពលភាពចំពោះសាលក្រមដោយរបៀបណា[28]។

## ii. ការពិភាក្សា

១៤. ការតវ៉ារបស់ដើមបណ្តឹងសាទុក្ខដែលថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ក្នុងការបដិសេធលើអញ្ញត្រកម្មធ្វើមិនចំពេលវេលាអំពីយុត្តាធិការបុគ្គលរបស់គាត់ គឺគ្មានមូលដ្ឋានទេ។ អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តយ៉ាងត្រឹមត្រូវនូវបទប្បញ្ញត្តិនានានៃវិធានដែលពាក់ព័ន្ធដែលតម្រូវឱ្យដើមបណ្តឹងសាទុក្ខលើកឡើងនូវការជំទាស់ណាមួយអំពីបញ្ហាយុត្តាធិការ នៅក្នុងសវនាការជំនុំជម្រះបឋម។ ដើមបណ្តឹងសាទុក្ខមិនគួរត្រូវបានអនុញ្ញាតឱ្យដើរខុសពីគន្លងនៃក្របខ័ណ្ឌនីតិវិធី

---

[27] *Rutaganda ទល់នឹង រដ្ឋអាជ្ញា*, សាលក្រម, ICTR-96-3-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR, ២៦ ឧសភា ២០០៣, [ចាប់ពីនេះតទៅហៅថា សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ *Rutaganda*,"], កថាខ័ណ្ឌទី២១ (ថ្លែងថា ការទទួលខុសត្រូវរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅពេលប្រឈមមុខនឹងការចោទប្រកាន់អំពីការភាន់ច្រឡំផ្នែកច្បាប់ គឺមិនមែន "ដើម្បីពិនិត្យទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហាច្បាប់ ដើម្បីកំណត់ថាតើបញ្ហាទាំងនោះមានសំអាងហេតុឬអត់ តែប៉ុណ្ណោះទេ ប៉ុន្តែតាមពិតក៏ត្រូវកំណត់អំពីថាតើបញ្ហាទាំងនោះត្រឹមត្រូវឬក៏អត់") ។

[28] សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ *Rutaganda*,, កថាខ័ណ្ឌទី២១ ។ *សូមអានផងដែរ រដ្ឋអាជ្ញា ទល់នឹង Galić*, សាលក្រម, IT-98-29-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ៣០ វិច្ឆិកា ២០០៦, កថាខ័ណ្ឌទី៧ ។

ដូចបានកំណត់នេះទេនៅក្នុងដំណាក់កាលចុងក្រោយនេះជាពិសេសស្របតាមស្មារតីនៃការបដិសេធមុនៗរបស់គាត់អំពីចេតនាណាមួយក្នុងការតវ៉ាអំពីបញ្ហាយុត្តាធិការបុគ្គល។

១៥. ដូចអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់រួចហើយអនុលោមតាមវិធាន៨៩ ដើមបណ្តឹងសាទុក្ខតម្រូវឱ្យលើកឡើងនូវអញ្ញត្រកម្មបឋមណាមួយអំពីបញ្ហាយុត្តាធិការ នៅពេលសវនាការបឋម[29]។ យោងតាម ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមលើសំណុំរឿង០០១ តាមរយៈការស្នើឱ្យភាគីនានាលើកនូវអញ្ញត្រកម្មបឋមណាមួយ ដែលខ្លួនមានរួមទាំងអញ្ញត្រកម្ម "ទាក់ទិននឹង ក) យុត្តាធិការរបស់អង្គជំនុំជម្រះ"[30] និងបានកត់សំគាល់ថា "ការខកខានមិនបានលើកអំពីអញ្ញត្រកម្មបឋមណាមួយនៅក្នុងសវនាការបឋម នាំឱ្យអញ្ញត្រកម្មនោះមិនអាចទទួលយកបានឡើយ"[31]។ ជាការឆ្លើយតបដើមបណ្តឹងសាទុក្ខបានលើកអំពីអញ្ញត្រកម្មបឋមមួយទាក់ទងនឹងអាជ្ញាយុកាលសម្រាប់បទល្មើសជាតិ"[32]។ គាត់មិនបានលើកអំពីអញ្ញត្រកម្មចំពោះយុត្តាធិការរបស់អង្គជំនុំជម្រះទេ[33]។

១៦. កំណត់ហេតុសវនាការបង្ហាញឱ្យឃើញថា ដើមបណ្តឹងសាទុក្ខបានជ្រើសរើសដោយដឹងខ្លួនជាមុន និងមានចេតនាមិនតវ៉ាចំពោះយុត្តាធិការបុគ្គលឡើយ។ ក្នុងពេលធ្វើសេចក្តីថ្លែងការណ៍បើកសវនា

---

[29] វិធាន៨៩.១ នៃវិធានផ្ទៃក្នុង ពេលនោះចែងថា (អញ្ញត្រកម្មបឋមទាក់ទិននឹង ក) យុត្តាធិការរបស់ អ.វ.ត.ក ... ត្រូវលើកនៅពេលសវនាការបឋម បើមិនដូច្នោះទេ មិនអាចទទួលយកបានឡើយ", វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី២), ៥ កញ្ញា ២០០៨ ["ចាប់ពីនេះតទៅហៅថា វិធាន (វិសោធនកម្មលើកទី២"), វិធានផ្ទៃក្នុង៨៩.១"] ។

[30] ប្រតិចារិកសវនាការ, សវនាការបឋម, ១៧ កុម្ភៈ ២០០៩, T.6 ។

[31] ប្រតិចារិកសវនាការ, សវនាការបឋម, ១៧ កុម្ភៈ ២០០៩, T.6 ។

[32] ប្រតិចារិកសវនាការ, សវនាការបឋម, ១៧ កុម្ភៈ ២០០៩, T.7 ។

[33] ប្រតិចារិកសវនាការ, សវនាការបឋម, ១៧ កុម្ភៈ ២០០៩, T.6-7, 11 (មេធាវីការពារក្តីបានលើកពីបញ្ហាអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មជាតិ ហើយនិងរយៈពេលនៃការឃុំខ្លួនមុនពេលសវនាការរបស់ដើមបណ្តឹងសាទុក្ខ ប៉ុន្តែមិនបានលើកអំពីបញ្ហាថាតើដើមបណ្តឹងឧទ្ធរណ៍គឺជា "មេដឹកនាំជាន់ខ្ពស់" ឬជាជនម្នាក់នៃ "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត" ទេ) ។

ការនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ នៅក្នុងចម្លើយតបមួយទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះសាលាដំបូង ដើមបណ្តឹងសាទុក្ខបានបញ្ជាក់អះអាងឡើងវិញយ៉ាងច្បាស់ ថាគាត់គ្មានបំណងតវ៉ាអំពីយុត្តាធិការរបស់ អ.វ.ត.ក ទេ[34]។ ជាពិសេស សហមេធាវីជាតិបានថ្លែងថា "នៅពេលសហព្រះរាជអាជ្ញាសួរថាតើខ្ញុំតវ៉ាអំពីបញ្ហាយុត្តាធិការដែរឬទេ ខ្ញុំគ្មានបំណងតវ៉ាអំពីបញ្ហាយុត្តាធិការទេ ពីព្រោះខ្ញុំបានដឹងច្បាស់ហើយ ប្រសិនបើខ្ញុំចង់លើកអំពីបញ្ហានេះ ម៉្លេះខ្ញុំបានលើកឡើងតាំងពីសវនាការបឋមម៉្លេះ"[35]។ អ្វីដែលគួរឱ្យកត់សំគាល់ ទោះបីការពិតអង្គជំនុំជម្រះសាលាដំបូង បានពឹងផ្អែកលើសេចក្តីថ្លែងការណ៍នេះយ៉ាងច្បាស់លាស់ នៅក្នុងសេចក្តីវិភាគរបស់ខ្លួនអំពីយុត្តាធិការបុគ្គលយ៉ាងណាក្តី[36] ក៏ដើមបណ្តឹងសាទុក្ខខកខានមិនបានលើកនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីដែរ ឬក៏ពន្យល់ថាហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅក្នុងការពឹងផ្អែកទៅលើសេចក្តីថ្លែងការណ៍នេះ។

១៧. សហព្រះរាជអាជ្ញា ក៏បានកត់សំគាល់ផងដែរថា បន្ថែមលើឱកាសនានាសម្រាប់ដើមបណ្តឹងសាទុក្ខលើកពីបញ្ហាយុត្តាធិការបុគ្គល ថាជាបញ្ហាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គាត់ក៏មាន

---

[34] ប្រតិចារិកសវនាការ, ១ មេសា ២០០៩, T.18-19 (លោក ការ សាវុត្ថ) ។

[35] ប្រតិចារិកសវនាការ, ១ មេសា ២០០៩, T.18 (លោក ការ សាវុត្ថ); សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី១៤, កំណត់សំគាល់ចុងទំព័រលេខ ១៨ ។ សហមេធាវីជាតិ បានបន្តទៀតដោយថ្លែងថា ["ដូច្នេះ អ្វីដែលខ្ញុំបានលើកឡើង មិនមែនដើម្បីតវ៉ាអំពីបញ្ហាយុត្តាធិការទេ។ ខ្ញុំគ្រាន់តែចង់ឱ្យតុលាការអនុវត្តតាមវិធាន៩៨.៧ តែប៉ុណ្ណោះ ទាក់ទិននឹងយុត្តាធិការរបស់តុលាការនេះ ទៅលើកូនក្តីរបស់ខ្ញុំ ប្រសិនបើគាត់មិនមែនជាមនុស្សជាន់ខ្ពស់បំផុត ឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតដែលត្រូវផ្តន្ទាទោស ដូច្នេះមិនត្រូវកាត់ទោសគាត់ទេ" ។ ប្រតិចារិកសវនាការ, ១ មេសា ២០០៩, T.18 (លោក ការ សាវុត្ថ)។ សហព្រះរាជអាជ្ញាកត់សំគាល់ថា វិធាន៩៨.៧ មិនមានអ្វីទាក់ទងនឹងយុត្តាធិការបុគ្គលទេ ផ្ទុយទៅវិញវាទាក់ទងនឹងវិសាលភាពនៃឧក្រិដ្ឋកម្មដែលអាចផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក ។ លើសពីនេះ ទោះបីមានភាសាខ្លះនៃសេចក្តីថ្លែងនេះហាក់ដូចជាជាប់ទាក់ទងនឹងយុត្តាធិការបុគ្គលក្តី ក៏សហមេធាវីជាតិបានដកចេញនូវភាពមិនប្រាកដប្រជានៅក្នុងគោលជំហររបស់មេធាវីការពារក្តីតាមរយៈការថ្លែងជាថ្មីម្តងទៀតនៅចុងយោបល់របស់គាត់ថា "ជាចុងក្រោយ ខ្ញុំគ្មានបំណងតវ៉ាអំពីយុត្តាធិការ [របស់ អ.វ.ត.ក] ទេ"។ ប្រតិចារិកសវនាការ, ១ មេសា ២០០៩, T.19 (លោក ការ សាវុត្ថ)។ *សូមអានផងដែរ* សារណាបណ្តឹងសាទុក្ខរបស់មេធាវី ,កថាខ័ណ្ឌទី៩៤ (ថ្លែងថា មេធាវីការពារក្តី "មិនជំទាស់នឹងសហព្រះរាជអាជ្ញាចាប់ផ្តើមតាំងពីដំបូង") ។

[36] សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី១៤, កំណត់សំគាល់ចុងទំព័រលេខ១៨ ។

ឱកាសពីមុនៗដើម្បីលើកពីអញ្ញត្រកម្មដូចគ្នានេះនៅក្នុងដំណាក់កាលមុនសវនាការ ប៉ុន្តែគាត់ខកខានមិនបានធ្វើដូច្នេះទេ។ ឧទាហរណ៍ ដើមបណ្តឹងឧទ្ធរណ៍សម្រេចមិនប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយស្តីពីទឡ្ហីករណ៍យុត្តាធិការ[37]។

១៨. ជាងនេះទៀត គ្មានអ្វីដែលថាមិនធម្មតា ឬអយុត្តិធម៌ឡើយ អំពីគំនិតដែលថា ភាគីមួយអាចនឹងបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការតវ៉ាអំពីយុត្តាធិការបុគ្គល ប្រសិនបើភាគីនោះខកខានមិនបានលើកពីបញ្ហានេះទាន់ពេលវេលា។ តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ជាទម្លាប់តម្រូវឱ្យភាគីនានាលើកពីអញ្ញត្រកម្មយុត្តាធិការឱ្យបានមុននៃការចាប់ផ្តើមដំបូងនៃសវនាការជំនុំជម្រះ[38]។ ទម្លាប់នៃការអនុវត្តបែបនេះលើកកំពស់ដល់ភាពសមស្រប និងប្រសិទ្ធភាពរបស់តុលាការ ដែលសារៈសំខាន់របស់វាមិនត្រូវមើលស្រាលឡើយនៅក្នុងបរិបទនៃការវិនិច្ឆ័យទោសចំពោះអំពើសាហាវយង់ឃ្នងដ៏រង្គាលដែលតាមប្រភេទនៃឧក្រិដ្ឋកម្មដូច្នេះ ត្រូវប្រើពេលវែង ស្មុគស្មាញ និងចំណាយច្រើន។ ដូចអង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY បានពន្យល់នៅក្នុងរឿងក្តី *Milutinović* ថា អញ្ញត្រកម្ម

---

[37] វិធាន៧៤.៣.ក នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី២) (រៀបរាប់អំពីទឡ្ហីករណ៍សម្រាប់បណ្តឹងឧទ្ធរណ៍មុនសវនាការ *ហើយក្នុងចំណោមបញ្ហាផ្សេងៗទៀត* ចែងថា ជនត្រូវចោទ ឬជនជាប់ចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "ការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក" ។

[38] *សូមអាន* វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY (វិសោធនកម្មលើកទី៤៤), ១០ ធ្នូ ២០០៩, វិធាន៧២ (ចែងថា ញត្តិស្នើសុំបឋមដែលតវ៉ាអំពីយុត្តាធិការត្រូវដាក់នៅក្នុងរយៈពេលមួយមានកំណត់ និងត្រូវសម្រេចនៅមុនពេលនៃការចាប់ផ្តើមសេចក្តីថ្លែងការណ៍បើកសវនាការ) ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTR វិសោធនកម្មថ្ងៃទី ១ តុលា ២០០៩, វិធាន៧២ ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូន SCSL ["ចាប់ពីនេះតទៅហៅថា វិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់តុលាការ SCSL] វិសោធនកម្ម ថ្ងៃទី ២៨ ឧសភា ២០១០, វិធាន៧២ ។ វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការពិសេសសម្រាប់លីបង់ (វិសោធនកម្មលើកទី៣, ១០ វិច្ឆិកា ២០០៩, វិធាន៩០ ។

អំពីយុត្តាធិការត្រូវតែបានលើកឡើងមុនពេលនៃការចាប់ផ្តើមសវនាការជំនុំជម្រះ "ដើម្បីកុំឱ្យកិច្ចការដ៏មហិមារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្លាយជាអ្វីដែលគេលែងត្រូវការ"[39]។

១៩. នៅក្នុងបែបផែនដូចគ្នានេះដែរ តាមការដាក់លក្ខខណ្ឌតម្រូវឱ្យគូភាគីនានានៅ អ.វ.ត.ក លើកឡើងនូវអញ្ញត្រកម្មអំពីយុត្តាធិការនៅពេលសវនាការបឋម វិធាន៨៩ធានាថា អង្គជំនុំជម្រះសាលាដំបូងបានដឹងជាមុន និងមានឱកាសពិចារណាលើអញ្ញត្រកម្មណាមួយអំពីបញ្ហានៃធម្មានុរូបជាមូលដ្ឋានរបស់ខ្លួនផ្ទាល់នៅមុនពេលចាប់ផ្តើមអនុវត្តសវនាការជំនុំជម្រះមួយ ដែលមានការអភិវឌ្ឍន៍យ៉ាងពេញលេញ និងមានធនធានដ៏ទូលំទូលាយ[40]។ វិធាន៨៩ ក៏បំរើឱ្យគោលបំណងគន្លឹះមួយផ្សេងទៀតដែរ ដែលធានាចំពោះភាគីនានាអំពីការជូនដំណឹងឱ្យបានគ្រប់គ្រាន់ថា បញ្ហាជាក់លាក់នានាត្រូវបានជជែក និងផ្តល់ឱកាសដល់ភាគីនានាស្របតាមនោះដែរ នៅពេលតវ៉ាករណីរឿងក្តីរបស់ពួកគេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សេចក្តីសម្រេចរបស់ដើមបណ្តឹងសាទុក្ខក្នុងការលើកអញ្ញត្រកម្មអំពីយុត្តាធិការរបស់គាត់នៅពេលចុងក្រោយបំផុតនៃសវនាការជំនុំជម្រះ យ៉ាងដូច្នេះដែលជាការផ្ទុយទៅនឹងវិធាន៨៩ យ៉ាងច្បាស់ក្រឡែត គឺមិនស្របទៅនឹងគោលបំណងគន្លឹះទាំងនេះទេ និងលើកឡើងពីបញ្ហានៃការរំលោភបំពានដំណើរការ។

---

[39] *រដ្ឋអាជ្ញា ទល់នឹង Milutinović* , សេចក្តីសម្រេចលើញត្តិរបស់ Nebojša Pavković ស្នើសុំឱ្យច្រានចោលការបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងរូបគាត់ ដោយសំអាងថាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានបង្កើតសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដោយខុសច្បាប់, IT-05-87-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ២១ កុម្ភៈ ២០០៨, កថាខណ្ឌទី១៥ ។

[40] ជាការពិតណាស់ដែលថាក្នុងខណៈដែលគេអាចថា អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចពន្យារពេលដោះស្រាយលើបញ្ហាយុត្តាធិការជាក់លាក់ណាមួយរហូតដល់ក្រោយពេលសវនាការជំនុំជម្រះបានចាប់ផ្តើមក៏ដោយ តែនេះជាសេចក្តីសម្រេចសម្រាប់អង្គជំនុំជម្រះសាលាដំបូង - មិនមែនមេធាវីការពារក្តីទេ ។ *សូមអាន រដ្ឋអាជ្ញា ទល់នឹង Kordić*, សេចក្តីសម្រេចលើញត្តិរបស់មេធាវីសុំឱ្យបញ្ជាក់បំភ្លឺ, IT-95-14-2, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ១៥ មករា ១៩៩៩, *ទំព័រទី*២ (បញ្ជាក់អះអាងថា ក្នុងខណៈដែលអង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិសម្រេចលើបញ្ហាយុត្តាធិការនៅក្នុងអម្លុងពេលមិននៅមុនពេលសវនាការជំនុំជម្រះក៏ដោយ ក៏ភាគីនានានៅតែតម្រូវឱ្យលើកឡើងនូវអញ្ញត្រកម្មយុត្តាធិការនៅមុនពេលនៃការចាប់ផ្តើមសវនាការជំនុំជម្រះដដែល) ។

២០. ទន្ទឹមនេះ ដូចមូលហេតុរៀបរាប់ពីខាងលើ សហព្រះរាជអាជ្ញាសូមរក្សាជំហរថា គ្មានការភាន់ច្រឡំឡើយ ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អញ្ញត្រកម្មអំពីយុត្តាធិការបុគ្គលរបស់ដើមបណ្តឹងសាទុក្ខ ធ្វើឡើងមិនចំពេលវេលា និងថាហេតុដូច្នេះមិនអាចទទួលយកបាន។

## ខ. អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងការបកស្រាយមាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង ដែលកំណត់ជំពូកមនុស្សពីរដាច់ពីគ្នា ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក

២១. ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការអះអាងអំពីយុត្តាធិការបុគ្គលរបស់ដើមបណ្តឹងសាទុក្ខ ត្រូវបានហាមឃាត់ដោយវិធាន៨៩ ក៏ដោយក៏តាមគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួន ការអះអាងនេះ បានបង្កើតនូវការវាយតម្លៃឯករាជ្យមួយអំពីយុត្តាធិការបុគ្គលនេះ។ ការធ្វើដូច្នេះ បានកំណត់ថា អ.វ.ត.ក មានយុត្តាធិការបុគ្គលទៅលើដើមបណ្តឹងសាទុក្ខថាជា "ជនម្នាក់នៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង" នៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងថាអាស្រ័យហេតុនេះ គេ"មិនចាំបាច់ពិនិត្យទៅលើបញ្ហាថាតើជនជាប់ចោទជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃកម្ពុជាប្រជាធិបតេយ្យ"[41]ឡើយ។

២២. ទោះបីជាសារណារបស់ដើមបណ្តឹងសាទុក្ខមិនច្បាស់លាស់ទាំងស្រុងលើចំណុចនេះក៏ដោយ ក៏គាត់ហាក់ដូចជាមានគោលជំហរថា គ្មានភាពខុសគ្នា (ឬភាពខុសគ្នាដ៏មានអត្ថន័យ) រវាងគំនិតដែលថា

[41] សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី២៥ ។

"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" និង "មេដឹកនាំជាន់ខ្ពស់"[42] និងថាជាការចាំបាច់ត្រូវបង្ហាញឱ្យឃើញថា ជនជាប់ចោទមានលក្ខណៈជា "មេដឹកនាំជាន់ខ្ពស់" ដើម្បីឱ្យគាត់ធ្លាក់ចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក[43]។

២៣. សហព្រះរាជអាជ្ញានៅតែរក្សាជំហរមិនផ្លាស់ប្តូរថា ជនជាប់ចោទ គឺជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" និងជា "មេដឹកនាំជាន់ខ្ពស់"[44]។ យ៉ាងណាក្តី សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដោយមិនគិតថាជនជាប់ចោទជា "មេដឹកនាំជាន់ខ្ពស់" សម្រាប់គោលបំណងនៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវថា យុត្តាធិការបុគ្គលនៅ អ.វ.ត.ក អាចត្រូវបានកំណត់ត្រឹមតែនៅលើមូលដ្ឋាននៃឋានៈរបស់បុគ្គលម្នាក់ៗ ថាជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ប៉ុណ្ណោះ។

---

42 *សូមអាន ឧទាហរណ៍* សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខ័ណ្ឌទី៣៣ ("ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ទេ គាត់ជាអ្នកដែលមានឋានានុក្រមទាបជាងគេ, គាត់គ្មានសិទ្ធិចេញបញ្ជា ឬធ្វើសេចក្តីសម្រេចទេ - មានការទទួលខុសត្រូវតិច ។ *ក្នុងឯកសារនេះដដែល,* កថាខ័ណ្ឌទី២២ (ថ្លែងថា ដើមបណ្តឹងសាទុក្ខ មិនស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ទេ ពីព្រោះ "គាត់មិនស្ថិតក្នុងជំពូកជាមេដឹកនាំជាន់ខ្ពស់ និងជនដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងរចនាសម្ព័ន្ធមេដឹកនាំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ") ។

43 *សូមអាន ឧទាហរណ៍* សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខ័ណ្ឌទី៣៣ (តវ៉ាថា ឌុច មិនអាចត្រូវបានគេពិចារណាថា ជាជនដែលទទួលខុសត្រូវខ្ពស់បំផុតបានទេ ដោយសារថា "ការទទួលខុសត្រូវរបស់បុគ្គល គឺផ្អែកទៅលើឋានានុក្រមនៃសិទ្ធិអំណាចតាមផ្លូវច្បាប់របស់គាត់" ហើយ ឌុច មានឋាននុក្រម "នៅថ្នាក់ក្រោម" ។ *ក្នុងឯកសារនេះដដែល,* កថាខ័ណ្ឌទី៣៧-៣៨ (ថ្លែងថា ច្បាប់ អ.វ.ត.ក "មិនអនុញ្ញាតឱ្យមានការចោទប្រកាន់ជនណាម្នាក់នៅថ្នាក់ទាប ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យឡើយ ដោយសារ "គេធ្វើតាមបញ្ជាពីថ្នាក់លើ") ។ *ក្នុងឯកសារនេះដដែល,* កថាខ័ណ្ឌទី១០០ ("អង្គជំនុំជម្រះ អ.វ.ត.ក មិនមានយុត្តាធិការទៅលើ [ឌុច] ទេ... ពីព្រោះ ឋានៈរបស់ ឌុច ទាំងនៅក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា គ្រាន់តែជាមូលដ្ឋាន និងឋានៈក្រោម មិនមែនឋានៈលើទេ") ។ *ក្នុងឯកសារនេះដដែល,* កថាខ័ណ្ឌទី៦៥ (អះអាងថា ច្បាប់ អ.វ.ត.ក "មិនគ្របដណ្តប់លើក្រុមនៃបុគ្គលដែលជាអ្នកអនុវត្តបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មទេ និងគ្មានអំណាចធ្វើសេចក្តីសម្រេចដោយខ្លួនឯងឡើយ" ប៉ុន្តែ "គ្របដណ្តប់ទៅលើក្រុមនៃបុគ្គលដែលមានអំណាចធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយដែលបានបង្កើតនូវគោលនយោបាយឧក្រិដ្ឋ") ។

44 សន្និដ្ឋានបញ្ចប់សវនាការស្តួរដេញដោលរបស់សហព្រះរាជអាជ្ញា ជាមួយនឹងឧបសម្ព័ន្ធ១-៥, សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អវតក/អជសដ, អង្គជំនុំជម្រះសាលាដំបូង, ១១ វិច្ឆិកា ២០០៩, E159/9, កថាខ័ណ្ឌទី២៤០-២៤៤ ។ សេចក្តីសន្និដ្ឋានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, កថាខ័ណ្ឌទី៦៤ (តវ៉ាថាអង្គជំនុំជម្រះសាលាដំបូងគួរតែបានរកឃើញថា ជនជាប់ចោទគឺជាមេដឹកនាំជាន់ខ្ពស់ម្នាក់ ។ ការអះអាងរបស់សហព្រះរាជអាជ្ញាបានសន្មតថា ការសម្រេចកំណត់បែបនេះគឺជាការចាំបាច់ មិនមែនសម្រាប់គោលបំណងនៃការកំណត់អំពីយុត្តាធិការបុគ្គលទេ ប៉ុន្តែសម្រាប់គោលបំណងនៃការវាយតម្លៃលើកត្តាបន្ធូបន្ថយទោសទាក់ទងនឹងការកាត់ទោស) ។

## i. បទដ្ឋាននៃការត្រួតពិនិត្យ

២៤. បញ្ហាអំពីការសន្និដ្ឋានត្រឹមត្រូវនៃបទប្បញ្ញត្តិច្បាប់មួយ គឺបញ្ហាច្បាប់។ ដូចបានរៀបរាប់ពីខាងលើ អនុលោមតាមវិធាន១០៤.១ អង្គជំនុំជម្រះតុលាការកំពូលមានសិទ្ធិអំណាចពិចារណាលើការចោទប្រកាន់អំពី "ការភាន់ច្រឡំណាមួយនៃបញ្ហាច្បាប់ដែលនាំឲ្យអស់សុពលភាពនៃសាលក្រម ឬ សេចក្តីសម្រេច" ហើយគេរំពឹងថា នឹងមានការវាយតម្លៃថាតើការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងត្រឹមត្រូវដែរឬទេ មិនមែនត្រឹមតែថាតើវាមានសំអាងហេតុតែប៉ុណ្ណោះនោះឡើយ[45]។

## ii. ការពិភាក្សា

២៥. មាត្រា១ និងមាត្រា២ នៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង កំណត់អំពីយុត្តាធិការបុគ្គលរបស់តុលាការទៅលើ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ទាក់ទិននឹងឧក្រិដ្ឋកម្ម ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិនានាដែលកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"[46]។

២៦. ដូចមានភស្តុតាងបញ្ជាក់ស្រាប់តាមរយៈសាលក្រម អង្គជំនុំជម្រះសាលាដំបូងបានយល់អំពីការប្រើសន្ធាន "**និង**" នៅក្នុងបទប្បញ្ញត្តិនានាទាំងនេះ ដែលកំណត់នូវប្រភេទមនុស្សពីរដាច់ពីគ្នាដែលស្ថិត

---

[45] *សូមអាន supra*, វាក្យខ័ណ្ឌ II(A)(i) ។

[46] ច្បាប់ អ.វ.ត.ក, មាត្រា១, ២ថ្មី ។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ២០០៣ [ចាប់ពីនេះតទៅហៅថា "កិច្ចព្រមព្រៀង អ.វ.ត.ក"], មាត្រា១, ២.១ ។

ក្នុងយុត្តាធិការរបស់ អ.វ.ត.ក: "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលកម្ពុជាប្រជាធិប-តេយ្យ[47]។ សេចក្តីវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង ក៏បង្ហាញផងដែរថា ខ្លួនយល់ថា មានបុគ្គលខ្លះអាចធ្លាក់ចូលក្នុងប្រភេទទាំងពីរ ប៉ុន្តែជនជាប់ចោទមិនចាំបាច់ទាល់តែស្ថិតក្នុងប្រភេទទាំងពីរ ជាមេដឹកនាំជាន់ខ្ពស់ <u>និង</u> ជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ទើបបានស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក នោះទេ[48]។

២៧. បន្ថែមទៅលើភាសាសាមញ្ញនៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អង្គជំនុំជម្រះសាលាដំបូងក៏បានពឹងផ្អែកផងដែរទៅលើប្រវត្តិនៃការធ្វើសេចក្តីព្រាងច្បាប់របស់ អ.វ.ត.ក សម្រាប់ជាសេចក្តីណែនាំចំពោះអត្ថន័យនៃពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[49]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូង បានលើកយោងសេចក្តីសន្និដ្ឋានរបស់ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ ឆ្នាំ១៩៩៩ ដែលថា គោលដៅពីរប្រភេទដែលត្រូវផ្តន្ទាទោសគឺ

---

[47] អង្គជំនុំជម្រះសាលាដំបូងបានលើកយោងដដែលៗអំពី "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ថាជាប្រភេទខុសគ្នា ។ *សូមអាន* សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី១៧ ("យុត្តាធិការបុគ្គល គឺត្រូវបានកំណត់ថា<u>មួយណាក៏បាន</u> ជា"មេដឹកនាំជាន់ខ្ពស់" ឬ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត...") (សង្កត់ន័យត្រង់ពាក្យដែលមានគូសបន្ទាត់ពីក្រោម) ។ *ក្នុងឯកសារនេះដដែល,* កថាខ័ណ្ឌទី១៩ ("ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក និងទាំងច្បាប់ អ.វ.ត.ក មិនបានកំណត់និយមន័យច្បាស់លាស់អំពី "មេដឹកនាំជាន់ខ្ពស់" ឬ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត") (សង្កត់ន័យត្រង់ពាក្យដែលមានគូសបន្ទាត់ពីក្រោម) ។

[48] *សូមអាន* សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី២៥ (រកឃើញថា ជនជាប់ចោទស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" និងថាបើដូច្នេះ គេមិនចាំបាច់ពិនិត្យលើបញ្ហាផ្សេងៗទៀតថាតើ ជនជាប់ចោទជាមេដឹកនាំជាន់ខ្ពស់ ឬក៏អត់នោះទេ) ។

[49] សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី១៩-២១ ។

"មេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវចំពោះការរំលោភ ព្រមទាំងជនទាំងឡាយដែលស្ថិតនៅថ្នាក់ក្រោមដែលជាប់ជំពាក់ដោយផ្ទាល់ក្នុងអំពើសាហាវយង់ឃ្នងធ្ងន់ធ្ងរបំផុត"[50]។

២៨. ការយល់របស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានគាំទ្របន្ថែមដោយការពិភាក្សាដេញដោលលើច្បាប់ អ.វ.ត.ក របស់សភាជាតិ ក្នុងខែតុលា ២០០៤។ នៅក្នុងអម្លុងពេលនៃការពិភាក្សាដេញដោលនេះ ឧបនាយករដ្ឋមន្ត្រី សុខ អាន បានពន្យល់ថា មាត្រា២ នៃច្បាប់ដែលបានស្នើឡើងនេះ គឺមានគោលបំណងដើម្បីអនុញ្ញាតឱ្យមានការចោទប្រកាន់នូវ "គោលដៅពីរប្រភេទ" (១) "មេដឹកនាំជាន់ខ្ពស់" ជាជនដែលមិនមែនជាអ្នកកាន់ "មុខតំណែងធម្មតា" និង(២) "ជនទាំងឡាយដែលមែនមិនជាមេដឹកនាំជាន់ខ្ពស់ប៉ុន្តែ ជាអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចមេដឹកនាំជាន់ខ្ពស់ដែរ"[51]។ ស្រដៀងគ្នានេះដែរ របាយការណ៍របស់ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ បានពន្យល់ថា "បញ្ជីនៃមន្ត្រីរដ្ឋាភិបាលថ្នាក់កំពូល និងមន្ត្រីបក្ស អាចមិនឆ្លើយតបទៅនឹងបញ្ជីនៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលនៅក្នុងជួរមេដឹកនាំរដ្ឋាភិបាលកំពូលទាំងនោះខ្លះ អាចត្រូវបានដកចេញពីអ្នកដែលមានការដឹងឮ និងការធ្វើសេចក្តីសម្រេចចិត្ត ហើយចំណែកខ្លះទៀតដែលមិនស្ថិតក្នុងតារាងនៃមេដឹកនាំជាន់ខ្ពស់ អាចមានតួនាទីសំខាន់នៅក្នុងអំពើសាហាវយង់ឃ្នងទាំងនេះ"[52]។

---

[50] សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី២០ (សង្កត់ន័យត្រង់ពាក្យដែលមានគូសបន្ទាត់ពីក្រោម) ។ របាយការណ៍របស់ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ, កថាខ័ណ្ឌទី១១០ ។

[51] ប្រតិចារិក, សម័យប្រជុំលើកទីមួយ, នីតិកាលទីបី របស់រដ្ឋសភាជាតិ, ៤-៥ តុលា ២០០៤, D288/6.9/8.22, ទំព័រ១៥-១៦ [ចាប់ពីនេះតទៅហៅថា "កិច្ចពិភាក្សាដេញដោលរបស់សភាជាតិ ឆ្នាំ២០០៤"] ។

[52] របាយការណ៍របស់ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ, កថាខ័ណ្ឌទី១០៩ ។

២៩. ដើមបណ្ដឹងសាទុក្ខ ខកខានមិនបានពន្យល់អំពីការភាន់ច្រឡំទៅតាមការយល់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺជាប្រភេទខុសគ្នា។ ផ្ទុយទៅវិញ គាត់ពឹងផ្អែកលើសេចក្ដីយោងនានាដែលនាំឱ្យមានការយល់ខុស[53] និងការរិះគន់ដែលគេដឹងជាទូទៅមួយ អំពីការផ្ដល់សំអាងហេតុនៅក្នុងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអំពីយុត្តាធិការបុគ្គល[54]។ ហេតុដូច្នេះ គាត់ខកខានមិនបានបំពេញបន្ទុកនៃភស្តុតាងរបស់គាត់ក្នុងការចោទប្រកាន់អំពីការភាន់ច្រឡំ នៅលើផ្នែកមួយនៃអង្គជំនុំជម្រះសាលាដំបូង។ តាមពិតដូចដែលបានពិភាក្សាខាងលើ អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងសេចក្ដីសន្និដ្ឋានចុងក្រោយរបស់ខ្លួន ដែលថាខ្លួនអាចរកឃើញនូវយុត្តាធិការបុគ្គលទៅលើ

---

[53] ឧទាហរណ៍ ដូចបានលើកឡើងក្នុងវាក្យខ័ណ្ឌ I នៃចម្លើយតបនេះ ដើមបណ្ដឹងសាទុក្ខអះអាងថា ច្បាប់ អ.វ.ត.ក "មិនអនុញ្ញាតឱ្យមានការផ្ដន្ទាទោសជនណាម្នាក់ដែលស្ថិតនៅថ្នាក់ក្រោម ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះពួកគេបានប្រព្រឹត្តតាមបញ្ជាពីថ្នាក់លើ" ។ សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី, កថាខ័ណ្ឌទី៣៧ ។ តាមការពិត មាត្រា២៩ នៃច្បាប់ អ.វ.ត.ក ចែងផ្ទុយពីនេះយ៉ាងច្បាស់ និងហាមឃាត់យ៉ាងច្បាស់អំពីការប្រើប្រាស់នូវបទបញ្ជារបស់ថ្នាក់លើធ្វើជាការការពារ ជាមធ្យោបាយគេចវះពីគណនេយ្យភាព ។ *សូមអាន* ច្បាប់ អ.វ.ត.ក, មាត្រា២៩.៤ ("ប្រការដែលថា ជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយមិនអាចជួយជនសង្ស័យនេះឱ្យរួចផុតពីការទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋនេះបានឡើយ") ។ *សូមអានផងដែរ* សាលក្រមសំណុំរឿងលេខ ០០១, កថាខ័ណ្ឌទី៥៥១-៥៥២ (ដោយដងស្រង់មាត្រា២៩ នៃច្បាប់អ.វ.ត.ក និងការរកឃើញថា ជនជាប់ចោទ "បានដឹងថាបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដើម្បីប្រព្រឹត្តបទល្មើស [ព្រហ្មទណ្ឌ] គឺជាអំពើខុសច្បាប់") ។ ស្រដៀងគ្នានេះដែរ នៅត្រង់កថាខ័ណ្ឌទី៣៥ នៃសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី, ដើមបណ្ដឹងសាទុក្ខ បានលើកយោងចោះៗចំពោះមាត្រា៩៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ហើយខកខានមិនបាននិយាយដល់មាត្រាបន្ទាប់ គឺមាត្រា១០០ ដែលបញ្ជាក់បំភ្លឺថា ជនណាដែលអនុវត្តសេចក្ដីបង្គាប់ ជាអនិត្យានុកូល មិនអាចគេចផុតពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌឡើយ ។ *សូមអាន* ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មាត្រា១០០ ("ក្នុងករណី ដែលសេចក្ដីបង្គាប់ជាអនិត្យានុកូល, ហើយអ្នកបញ្ជាជាអាជ្ញាធរធម្មានុរូបនោះ, ចៅក្រម ត្រូវថ្លឹងមើលតាមការណ៍គួរ នូវភាពនៃការទទួលខុសត្រូវ ក្នុងបទព្រហ្មទណ្ឌរបស់ភ្នាក់ងារអ្នកសម្រេចការណ៍នោះ") ។

[54] *សូមអាន* សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី, កថាខ័ណ្ឌទី២៥ (ថ្លែងថា "អង្គជំនុំជម្រះ*បានយល់ស្របដោយមិនត្រឹមត្រូវជាមួយនឹងការសំអាងលេសដែលគ្មានមូលដ្ឋាន [នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ] គតិយុត្តិសមហេតុផលរបស់ដើមចោទ* និងដែលការិយាសហព្រះរាជអាជ្ញាពឹងផ្អែក ដើម្បីដាក់ការចោទប្រកាន់ទៅលើគាត់ ដោយចោទគាត់ថា ជាជនម្នាក់នៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងពិពណ៌នាមន្ទីរស-២១ ថាជាមណ្ឌលសន្តិសុខដ៏សំខាន់ ធ្វើប្រតិបត្តិការពាសពេញប្រទេស ។ ការសំអាងបែបនេះ *ពុំមានលក្ខណៈគត្តៈក្នុងវិស្ស័យច្បាប់* និងមិនអាចប្រើប្រាស់សម្រាប់កំណត់អំពីឋានៈរបស់ជនម្នាក់ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ") (សង្កត់ន័យត្រង់ឃ្លាអក្សរទ្រេត) ។ *ក្នុងឯកសារនេះដដែល,* កថាខ័ណ្ឌទី២៥ (ការលើកយោងដ៏ពិបាកយល់ និងគ្មានការបញ្ជាក់ច្បាស់លាស់អំពី "ទ្រឹស្ដីច្បាប់ដែលកំណត់អំពីជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលតាមការអះអាងថា មិនរាប់បញ្ចូលជនដែលទទួលបញ្ជាពីថ្នាក់លើ) ។

ដើមបណ្ដឹងសាទុក្ខថាជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយមិនបាច់គិតថាគាត់ជា "មេដឹកនាំជាន់ខ្ពស់" នោះឡើយ។

## គ. អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំនៅក្នុងការរកឃើញថាខ្លួនមានយុត្តាធិការទៅលើដើមបណ្ដឹងសាទុក្ខ សំអាងលើឋានៈរបស់គាត់ជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"

៣០. វិធាន៨៩ មិនបានបញ្ជាក់ជាក់លាក់ថាតើ បទដ្ឋានណាមួយដែលគួរអនុវត្តសម្រាប់ការពិនិត្យទៅលើការតវ៉ាអំពីយុត្តាធិការ។ ប៉ុន្តែដើមបណ្ដឹងសាទុក្ខសន្មតថា បទដ្ឋាននៃភស្តុតាងដូចគ្នាសម្រាប់ការសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ "ហួសពីវិមតិសង្ស័យ" ក៏អនុវត្តបានដែរ ចំពោះការវាយតម្លៃអំពីយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះសាលាដំបូង[55]។ ដើមបណ្ដឹងសាទុក្ខមិនបានផ្ដល់ការគាំទ្រចំពោះគោលជំហរនេះទេ ដែលនេះស្ថិតនៅកាន់តែឆ្ងាយពីភាពជាក់ស្ដែង។

៣១. នៅខណៈដែលសហព្រះរាជអាជ្ញាមិនបានដឹងអំពីអាជ្ញាធរកម្ពុជា ឬអន្តរជាតិណាមួយដែលពាក់ព័ន្ធផ្ទាល់លើចំណុចនេះ ក្របខ័ណ្ឌស្ថាប័នរបស់ អ.វ.ត.ក ជាពិសេស តួនាទីដាច់ពីគ្នារបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត នៅក្នុងការជ្រើសរើស និងបញ្ជាក់អំពីជនសង្ស័យសម្រាប់ការចោទប្រកាន់ឲ្យដឹងថា បទដ្ឋាននៃភស្តុតាង *"ឃើញមួយក្រឡេកភ្នែក"* ឬគុណភាពនៃភស្តុតាងភវនីយភាព គឺជាការសមស្របណាស់ទៅហើយ[56]។

---

[55] *សូមអាន* សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី, កថាខ័ណ្ឌទី៦៨-៦៩, ៩៧ ។

[56] ការអនុវត្តបទដ្ឋាន *ភស្តុតាងឃើញមួយក្រឡេកភ្នែក* គុណភាពនៃភស្តុតាងភវនីយភាព គឺស្របតាមទម្លាប់នៃការអនុវត្តអន្តរជាតិជាទូទៅ ដែលអង្គជំនុំជម្រះសវនាការផ្ដល់នូវការពេញចិត្តដ៏សំខាន់ចំពោះការកំណត់របស់សហព្រះរាជអាជ្ញាដែលថា ជនម្នាក់ស្ថិតក្នុងន័យនៃព្រំដែននៃច្បាប់ជាពិសេស ប្រសិនបើការកំណត់នោះត្រូវបានពិនិត្យដោយចៅក្រមមួយរូបដែលធ្វើការបញ្ជាក់អះអាង។

៣២. ដោយមិនគិតថា ទោះបីសន្មតថា បទដ្ឋានសម្រាប់ការពិនិត្យលើការសម្រេចអំពីយុត្តាធិការ ពិតជា "ហួសពីវិមតិសង្ស័យ" ដូចដើមបណ្តឹងសាទុក្ខបានអះអាងក៏ដោយ ក៏ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខ្លួនមានយុត្តាធិការបុគ្គលទៅលើជនជាប់ចោទ គឺមានការគាំទ្រយ៉ាងល្អតាមរយៈការរកឃើញអង្គហេតុដែលបានធ្វើឡើងនៅក្នុងសាលក្រម និងថាបើដូច្នេះបានបំពេញតាមបទដ្ឋានសម្រាប់ការត្រួតពិនិត្យដែលពាក់ព័ន្ធ។ ទន្ទឹមនេះ ដើមបណ្តឹងសាទុក្ខខកខានមិនបានបង្ហាញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាខ្លួនមានយុត្តាធិការបុគ្គល ថាជាការភាន់ច្រឡំនោះទេ។

---

*សូមអានឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Brima*, សាលក្រម, SCSL-2004-16-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ SCSL, ២២ កុម្ភៈ ២០០៨ [ចាប់ពីនេះតទៅហៅថា "សាលក្រមលើបណ្តឹងឧទ្ធរណ៍របស់ *Brima*" ], កថាខ័ណ្ឌទី២៨០-២៨៤, ជាពិសេស ២៨១ (រកឃើញថា មានតែរដ្ឋអាជ្ញាតែម្នាក់គត់ដែលមានឆន្ទានុសិទ្ធិក្នុងការកំណត់ថាតើនរណាដែលស្ថិតក្នុងវិសាលភាពនៃភាសាដែលថា "ជនទាំងឡាយ ដែលទទួលខុសត្រូវដ៏ធំធេង" នៅក្នុងច្បាប់លក្ខន្តិកៈរបស់ SCSL ដោយហេតុថា ផ្ទុយពីអង្គជំនុំជម្រះសាលាដំបូង រដ្ឋអាជ្ញាមានអត្ថប្រយោជន៍ខាងចំណេះដឹងយ៉ាងទូលំទូលាយដែលទទួលបានតាមរយៈកិច្ចស៊ើបសួរមុនពេលសវនាការ ទៅក្នុងរឿងជម្លោះនោះ") ។ វិធាន២៨ របស់តុលាការ ICTY (ចែងថា ការិយាល័យ ដែលមានសមាសភាគ ប្រធាន អនុប្រធាន និងចៅក្រមប្រធានសវនាការរបស់ ICTY ត្រូវពិនិត្យ "ថាតើការចោទប្រកាន់ ឃើញមួយក្រឡេកភ្នែក ផ្តោតទៅលើមេដឹកនាំជាន់ខ្ពស់បំផុតម្នាក់ ឬច្រើនជាងនេះ ដែលសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត") ។ វិធាន៤៧ របស់តុលាការ ICTY (ចែងថា "ការចោទប្រកាន់របស់រដ្ឋអាជ្ញា ត្រូវមានការបញ្ជាក់ពីចៅក្រមមួយរូបដែលគាត់ត្រូវតែពេញចិត្តថា "មានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តល់នូវទឡ្ហីករណ៍ដែលមានសំអាងហេតុដែលឱ្យគេជឿបានថាជនសង្ស័យពិតជាប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់តុលាការ")។ *សូមអានផងដែរ រដ្ឋអាជ្ញា ទល់នឹង Brđanin* សេចក្តីសម្រេចលើញត្តិស្នើសុំឱ្យលើកលែងការចោទប្រកាន់, IT-99-36, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY, ៥ តុលា ១៩៩៩, កថាខ័ណ្ឌទី១៥ (សម្រេចថា នៅពេលអង្គជំនុំជម្រះសាលាដំបូង កំពុងតែពិនិត្យទៅលើអញ្ញត្រកម្មចំពោះយុត្តាធិការ អង្គជំនុំជម្រះមិនចាំបាច់ពិនិត្យថាតើគេមានភស្តុតាងសម្រាប់បញ្ជាក់អំពីអង្គហេតុនានាដែលបានចោទប្រកាន់ដែរឬក៏អត់នោះឡើយ ដោយហេតុថា "យុត្តាធិការរបស់តុលាការ [...] ពឹងផ្អែកទៅលើតែអ្វីដែលបានអះអាងនៅក្នុងការចោទប្រកាន់នោះតែប៉ុណ្ណោះ")។ *រដ្ឋអាជ្ញា ទល់នឹង Delić*, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទំដែលតវ៉ាអំពីយុត្តាធិការរបស់តុលាការ, IT-04-83-AR72, អង្គជំនុំជម្រះ សាលាឧទ្ធរណ៍នៃតុលាការ ICTY, ៨ ធ្នូ ២០០៥, កថាខ័ណ្ឌទី១១ (សម្រេចថានៅខណៈដែលភាពគ្រប់គ្រាន់នៃការចោទប្រកាន់នៅក្នុងដីកាចោទប្រកាន់រួមបង្កើតឱ្យមានបញ្ហាយុត្តាធិការ បញ្ហាអំពីភាពគ្រប់គ្រាន់នៃភស្តុតាងដែលគាំទ្រចំពោះការចោទប្រកាន់នោះ មិនមែនជាបញ្ហាយុត្តាធិការទេ) ។

## i. បទដ្ឋាននៃការត្រួតពិនិត្យ

៣៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថា បញ្ហាដែលថា តើដើមបណ្តឹងសាទុក្ខគឺជាជនម្នាក់នៃ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើង ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យដែរឬអត់[57]។ អនុលោមតាមវិធាន១០៤ អង្គជំនុំជម្រះតុលាការកំពូលមានសិទ្ធិអំណាចពិនិត្យលើការចោទប្រកាន់អំពី "កំហុសនៃអង្គហេតុដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌"[58]។ តុលាការព្រហ្មទណ្ឌអន្តរជាតិនានាពិនិត្យលើការចោទប្រកាន់អំពីការភាន់ច្រឡំបែបនេះ ដោយអនុលោមតាមបទដ្ឋាននៃការត្រួតពិនិត្យមួយដែលមានការគោរពយ៉ាងហ្មត់ចត់[59]។ ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានថ្លែងថា នៅពេលបកស្រាយអំពីភាសានៃការត្រួតពិនិត្យបណ្តឹងសាទុក្ខដូចគ្នាបេះបិទ "ដើមបណ្តឹងសាទុក្ខនឹងទទួលបានជោគជ័យ វៀរលែងតែ គាត់អាចបង្ហាញឲ្យឃើញថា <u>គ្មានអ្នកជំនុំជម្រះអង្គហេតុ)សមហេតុផល</u> បានសម្រេច ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើ"[60]។ នៅក្នុង

---

[57] សាលក្រមបណ្តឹងឧទ្ធរណ៍ *Kvocka,* កថាខ័ណ្ឌទី១៩២-១៩៦ (ការអនុវត្តការភាន់ច្រឡំនៃបទដ្ឋានអង្គហេតុនៃការត្រួតពិនិត្យបណ្តឹងឧទ្ធរណ៍នៅពេលពិនិត្យថាតើអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅក្នុងការអនុវត្តបទដ្ឋានច្បាប់ចំពោះអង្គហេតុនៃសំណុំរឿងដែរឬទេ។ បទដ្ឋានច្បាប់នេះ គឺថាតើទង្វើរបស់ជនជាប់ចោទ "ជំរុញបន្ថែមទៅលើគោលបំណងរួម ដើម្បីតម្រូវទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ ជាសហចារីនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម") ។

[58] វិធាន១០៤.១ នៃវិធានផ្ទៃក្នុង ។

[59] *សូមអាន ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង* Rutaganda, សាលក្រមបណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី២១ (ថ្លែងថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវបង្ហាញឲ្យឃើញនូវ "ការពេញចិត្តក្នុងកំរិតខ្ពស់មួយ... ចំពោះការសម្រេចលើអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង") ។ *រដ្ឋអាជ្ញា ទល់នឹង Tadić*, សាលក្រម, IT-94-1, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ១៥ កក្កដា ១៩៩៩ [ចាប់ពីនេះតទៅហៅថា "សាលក្រមបណ្តឹងឧទ្ធរណ៍ *Tadić* "], កថាខ័ណ្ឌទី៦៤ (ចែងថា "អង្គជំនុំជម្រះសាលាឧទ្ធរណ៍ អាចដាក់ការសម្រេចរបស់ខ្លួនជំនួសការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងបានតែ "ភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងបានពឹងផ្អែក *មិនអាចត្រូវបានគេទទួលយកដោយមិនសមហេតុផលដោយជនម្នាក់ដែលប្រកបដោយហេតុផល តែប៉ុណ្ណោះ*") (សង្កត់ន័យត្រង់អក្សរទ្រេត) ។

[60] *រដ្ឋអាជ្ញា ទល់នឹង* *Ndindababizi*, សាលក្រម, ICTR-01-81-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR, ១៦ មករា ២០០៧ [ចាប់ពីនេះតទៅហៅថា "សាលក្រមបណ្តឹងឧទ្ធរណ៍ *Ndindababizi*"] កថាខ័ណ្ឌទី៨៦ (សង្កត់ន័យត្រង់ឃ្លាមានគូសបន្ទាត់ពីក្រោម) ។

រឿងក្តី *Kupreškić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានពន្យល់បន្ថែមអំពីសនិទានភាពសម្រាប់ឲ្យមានការយល់ព្រមតាមការរកឃើញ នូវអង្គហេតុរបស់អង្គជំនុំជម្រះសវនាការ៖

មូលហេតុដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នឹងមិនរំខាន សូម្បីតែបន្តិចបន្តួចក្តី អំពីការរកឃើញនូវអង្គហេតុដោយអង្គជំនុំជម្រះសាលាដំបូងណាមួយ គឺត្រូវបានគេដឹងឮជាទូទៅ។ អង្គជំនុំជម្រះសាលាដំបូងមានអត្ថប្រយោជន៍ចំពោះការសង្កេតលើសាក្សីនានាដោយផ្ទាល់ ដូច្នេះ គាត់ស្ថិតក្នុងជំហរមួយដ៏ប្រសើរជាងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើការវាយតម្លៃអំពីភាពអាចទុកចិត្តបាន និងជឿជាក់បាននៃភស្តុតាង។ ស្របគ្នានេះដែរ ជាបឋមអង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់ថាតើសាក្សីម្នាក់អាចជឿជាក់បានឬទេ និងត្រូវសម្រេចថាតើសក្ខីកម្មរបស់សាក្សីណា ដែលជាទីពេញចិត្តជាងគេ ដោយពុំចាំបាច់បញ្ចេញសម្តែងច្បាស់លាស់គ្រប់ជំហាននិមួយៗ ក្នុងការផ្តល់សំអាងហេតុដើម្បីធ្វើឲ្យសម្រេចបាននូវសេចក្តីសម្រេចណាមួយនៅលើចំណុចទាំងនេះទេ[61]។

*សូមអានផងដែរ* សាលក្រមបណ្តឹងឧទ្ធរណ៍ *Tadić*, កថាខ័ណ្ឌទី៦៤ (ថែងថា "ជាការសំខាន់ដែលត្រូវកត់សំគាល់ថា ចៅក្រមពីររូប ដែលចៅក្រមទាំងពីរសុទ្ធតែជាចៅក្រមប្រកបដោយហេតុផល អាចធ្វើឲ្យសម្រេចបាននូវសេចក្តីសន្និដ្ឋានខុសគ្នាមួយ ដោលឈរលើមូលដ្ឋាននៃភស្តុតាងដូចគ្នា") ។

[61] *រដ្ឋអាជ្ញា ទល់នឹង* *Kupreškić*, សាលក្រមបណ្តឹងឧទ្ធរណ៍, IT-95-16-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ២៣ តុលា ២០០១, កថាខ័ណ្ឌទី៣២ ។

៣៤. ភាសាដែលថា "ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើយុត្តិធម៌" ត្រូវបានគេបកស្រាយដែលមានន័យថា "ជាលទ្ធផលដ៏អយុត្តិធម៌យ៉ាងធំមួយ នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដូចជានៅពេលចុងចោទត្រូវបានកាត់ឱ្យជាប់ទោស ទោះបីមានកង្វះខាតភស្តុតាងអំពីធាតុផ្សំនៃបទល្មើសសំខាន់ៗក៏ដោយ"[62]។

## ii. ការពិភាក្សា

៣៥. ដូចបានបញ្ជាក់ខាងលើ នៅក្នុងសាលក្រមរបស់ខ្លួនអង្គជំនុំជម្រះសាលាដំបូងបានធ្វើការកំណត់សម្រេចដោយឯករាជ្យមួយអំពីយុត្តាធិការបុគ្គលដែលរកឃើញថា យុត្តាធិការនេះត្រូវបានបង្កើតឡើងចាប់តាំងពីពេលដែលជនជាប់ចោទ គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូបក្នុងចំណោម "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនានា"[63]។ ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង គឺមានភាពសមហេតុសមផលគួរឱ្យកត់សំគាល់ និងដែលមានការគាំទ្រដោយការរកឃើញនូវអង្គហេតុដ៏ច្រើនសន្ធឹកសន្ធាប់។

---

[62] *រដ្ឋអាជ្ញា ទល់នឹង Furundzija*, សាលក្រមបណ្តឹងឧទ្ធរណ៍, IT-95-17/1-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ២៣ កក្កដា ២០០០, កថាខ័ណ្ឌទី៣៧, សាលក្រមបណ្តឹងឧទ្ធរណ៍, ICTR-96-13-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR, ១៦ វិច្ឆិកា ២០០១, កថាខ័ណ្ឌទី១៧, ក.២៤(ដកស្រង់ភាសាដូចគ្នា)។ ទោះបីជាសហព្រះរាជអាជ្ញានៅតែរក្សាជំហរថា ការអនុវត្តមាត្រា១ និង២ នៃច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង ចំពោះជនជាប់ចោទជាបញ្ហានៃអង្គហេតុដែលត្រូវពិនិត្យដោយអនុលោមតាមការភាន់ច្រឡំ នៃបទដ្ឋាន អង្គហេតុក៏ដោយ ក៏សេចក្តីសន្និដ្ឋានដូចគ្នាគួរតែសម្រេចឱ្យបានប្រសិនបើការភាន់ច្រឡំផ្នែកច្បាប់ត្រូវបានអនុវត្ត ។

[63] *សូមអាន* សាលក្រមសំណុំរឿងលេខ ០០១ កថាខណ្ឌទី១៦-២៥។ ដើមបណ្តឹងឧទ្ធរន៍បានស្នើយោបល់ដោយយល់ច្រឡំនៅក្នុងបណ្តឹងសាទុក្ខថាការសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធណ៍ដែលថាខ្លួនមានយុត្តាធិការបុគ្គលគឺដោយផ្អែកលើមូលដ្ឋានតែមួយគត់គឺការច្រានចោលរបស់ខ្លួនចំពោះការជំទាស់របស់មេធាវីការពារក្តីអនុលោមតាមវិធាន៨៧នៃវិធានផ្ទៃក្នុង។*សូមអាន* សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី, កថាខណ្ឌទី៦៦។ ការជូនដំណឹងអំពីការដាក់បណ្តឹងសាទុក្ខរបស់ដើមបណ្តឹងសាទុក្ខដែលបានប្រកាន់យកជំហរនេះយ៉ាងច្បាស់លាស់ជាងនេះ ដែលថ្លែងថា "អង្គជំនុំជម្រះសាលាដំបូងបានពិចារណាតែទៅលើយុត្តាធិការកម្មវត្ថុនៃករណីរឿង, យុត្តាធិការពេលវេលា, និងយុត្តាធិការដែនដីរបស់ខ្លួនតែប៉ុណ្ណោះ និងពឹងផ្អែកលើយុត្តាធិការទាំងនោះដើម្បីកាត់ក្តីឱ្យដើមបណ្តឹងឧទ្ធរណ៍មានទោស]ពីបទឧក្រិដ្ឋកម្មនានានៅមន្ទីរស-២១..."។*សូមអាន* សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី, កថា ខណ្ឌទី៨។

៣៦. ជាក់ស្តែង សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាប់ចោទគឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតមួយរូបក្នុងចំណោម "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនានា" ត្រូវបានគាំទ្រដោយការរកឃើញនានារបស់ខ្លួនដែលទាក់ទងអំពី (១) ស្ថានទម្ងន់នៃបទឧក្រិដ្ឋរបស់គាត់ដែលរួមទាំងចំនួននៃជនរងគ្រោះ និងព្រឹត្តិហេតុនានា ហើយនិងទំហំនៃភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្មទាំងនោះ។ និង(២) កំរិតនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែលរាប់បញ្ចូលទាំង (ក)ចំនួនដ៏ច្រើនសន្ធឹកនៃអ្នកនៅក្រោមបង្គាប់របស់ជនជាប់ចោទ និងឋានានុក្រមតាមលំដាប់ថ្នាក់នៅពីលើគាត់ដែលមានចំនួនតិច និង (ខ)ស្ថេរភាព និងភាពអចិន្ត្រៃយ៍នៃមុខតំណែងរបស់ជនជាប់ចោទនៅក្នុងទូទាំងអម្តុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[64]។

---

[64] អង្គចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY បានផ្អែកលើគោលគំនិតទាំងពីរនោះ-ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មនិងកំរិតនៃ ការចូលរួម-នៅពេលពិចារណាអំពីថាតើជនសង្ស័យមានថ្លិតនៅក្នុងពាក្យពេចន៍ដែលកំរិតកំណត់ដែលគេប្រើនេះស្រដៀងគ្នានេះដែរ ឬ ទេ?-គឺបានន័យថា "មេដឹកនាំជាន់ខ្ពស់បំផុតដែលត្រូវបានសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត"។ សម្រាប់ស្ថានទម្ងន់នៃឧក្រិដ្ឋកម្ម, *សូមអាន ករណីរឿក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Lukić* , សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Martin Lukić ស្តីពីការបញ្ជូនសំណុំរឿង , សំណុំរឿង លេខ IT-98-32/1-AR11Bis, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី១១ កក្កដា ២០០៧ , កថាខណ្ឌទី២៥(ដែលរកឃើញភស្តុតាងថាឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ជនជាប់ចោទមានលក្ខណៈ "ជាក់ស្តែងគឺមានភាពធ្ងន់ធ្ងរ" ដោយឧក្រិដ្ឋកម្មទាំងនោះរួមបញ្ចូលនូវព្រឹត្តិហេតុដែលគួរឱ្យភ័យរន្ធត់មួយចំនួនដែលជាលទ្ធផលគឺបណ្តាលឱ្យមានការស្លាប់មនុស្សជាសរុបមានចំនួន១៥០នាក់")។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Jankovic* , សេចក្តីសម្រេចលើករណីការបញ្ជូនសំណុំរឿង តាមវិធាន១១ស្ទួន , សំណុំរឿងលេខ IT-96-23/2-AR11bis.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី១៥ វិច្ឆិកា ២០០៥ កថាខណ្ឌទី២២ (ដែលយកចិត្តទុកដាក់ " ទៅលើទាំងវិសាលភាពភូមិសាស្ត្រ និងទាំងវិសាលភាពពេលវេលា នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ផង ក៏ដូចជាទៅលើចំនួននៃជនរងគ្រោះដែលត្រូវបានរងផលប៉ះពាល់"នៅពេលធ្វើការវាយតម្លៃអំពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់)។ ចំពោះកំរិតនៃការចូលរួម របស់ជនជាប់ចោទ, *សូមអាន ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Ademi* សេចក្តីសម្រេចឱ្យបញ្ជូនទៅឱ្យអាជ្ញាធរនៃសាធារណរដ្ឋក្រូអាស៊ីអនុលោមតាមវិធាន១១ស្ទួន, សំណុំរឿងលេខ IT-04-78-PT, អងង្គចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY, ចុះថ្ងៃទី១៤កញ្ញា ២០០៥, កថាខណ្ឌទី២៩ (ដែលនិយាយថា បញ្ហាកំរិតនៃការទទួលខុសត្រូវរបស់ជនចាប់ចោទគួរតែត្រូវបានបកស្រាយដើម្បីឱ្យមានការរាប់បញ្ចូលទាំង "ឋានៈជាផ្លូវការ ជាក់ស្តែង" របស់ ជនជាប់ចោទផង និងទាំង "តួនាទីជាក់ស្តែង"នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មផង)។*ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Dragomir Milošević* , សេចក្តីសម្រេចលើករណីការបញ្ជូនសំណុំរឿង អនុលោមតាមវិធាន១១ស្ទួន , សំណុំរឿងលេខ IT-98-29/1-PT, អង្គចៅក្រមបញ្ជូនសំណុំរឿងនៃតុលាការ ICTY, ចុះថ្ងៃទី៨ កក្កដា ២០០៥, កថាខណ្ឌទី២២ [" សេចក្តីសម្រេចក្នុងការបញ្ជូន សំណុំរឿងរបស់ *Dragomir Milošević*"], កថាខណ្ឌទី២២ , (ដែលបញ្ជាក់ថា ការវិភាគអំពីថាជនជាប់ចោទត្រូវបានចាត់ចូលនៅក្នុងចំណាត់ថ្នាក់ "ពួកមេដឹកនាំជាន់ខ្ពស់បំផុតដែលត្រូវបានសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬទេនោះ" គឺតម្រូវឱ្យមានការវាយតម្លៃមួយអំពី *តួនាទីតាមផ្លូវច្បាប់និងតួនាទីជាក់ស្តែង* និងពីមុខងាររបស់ជនជាប់ចោទ)។ *ដូចគ្នានឹងខាងលើ* , កថាខណ្ឌទី ២៣ (ដោយយកចិត្តទុកដាក់

៣៧. ដើមបណ្តឹងសាទុក្ខបានធ្វើការកត់សំគាល់ដោយខ្លួនឯងថា -នៅពេលពិនិត្យអំពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់- ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY បានយកមកពិចារណាលើ "ចំនួននៃជនរងគ្រោះ ដែនកំណត់ភូមិសាស្ត្រ និងពេលវេលា របៀបដែលពួកគេត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ព្រមទាំងចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង"[65]។ ក្នុងករណីរឿងបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា " ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរស-២១ ជនជាប់ចោទបានរៀបចំចាត់ចែង និងពង្រឹងប្រពន្ធ័គ្រប់គ្រងមួយអស់រយៈពេលជាងបីឆ្នាំ ដែលបណ្តាលឱ្យមានការសម្លាប់ជីវិតមនុស្សមិនតិចជាង១២.២៧២ នាក់ ហើយភាគច្រើនក្នុងចំណោមជនរងគ្រោះទាំងនោះ ត្រូវបានគេធ្វើទារុណកម្មតាមលក្ខណៈជាប្រពន្ធ័ផងដែរ"[66]។ ការធ្វើទារុណកម្មនៅមន្ទីរស-២១ រួមមានវិធីសាស្ត្រផ្សេងៗ ដូចជាការវាយដំដោយរំពាត់ផ្តៅ ការឆក់ខ្សែភ្លើង ការជ្រមុជក្បាលចូលក្នុងទឹក និងការធ្វើឱ្យថប់ដង្ហើមដោយថង់ប្លាស្ទិក[67]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់បន្ថែមទៀតថា ឧក្រិដ្ឋកម្មជាច្រើនដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ត្រូវបានប្រព្រឹត្តដោយមានលក្ខណៈឃោរឃៅ"[68] និងថា "អ្នកជាប់ឃុំ

---

ទៅលើប្រការដែលថា មេដឹកនាំមាន "ឋានានុក្រមតែមួយថ្នាក់" ប៉ុណ្ណោះ នៅពីលើជនជាប់ចោទនៅក្នុងការកំណត់សម្រេចថា ជននេះគួរបានធ្វើការជំនុំជម្រះក្តីនៅថ្នាក់អន្តរជាតិ )។ *ដូចគ្នានឹងខាងលើ* កថាខណ្ឌទី២៣ (ដែលកត់សំគាល់ជាពិសេសថា ជនចាប់ចោទគឺជាមេបញ្ជាការកងទ័ពជាអចិន្ត្រៃយ៍ ដែលផ្ទុយទៅនឹង ជាមេបញ្ជាការ*សម្រាប់ពេលមានករណីពិសេសណាមួយ* ឬមេបញ្ជាការកងទ័ពស្តីទីដែលកំពុងតែមានបញ្ហានេះ "នៅក្នុងរយៈពេលដ៏យូរអង្វែងដែលហួសពីមួយឆ្នាំ" នៅក្នុងពេលធ្វើការកំណត់ថាជនជាប់ចោទគួរបានធ្វើការជំនុំជម្រះក្តីនៅថ្នាក់អន្តរជាតិវិញប្រសើរជាងជំនុំជម្រះនៅថ្នាក់ជាតិ)។

[65]សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី, កថាខណ្ឌទី១៩។

[66] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៥៩៧។

[67] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២៤១។

[68] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៦០៣។

នៅមន្ទីរស២១ ដែលរួមមានទាំងកូនក្មេង សហព័ទ្ធ និងសមាជិកក្រុមគ្រួសារផ្សេងទៀតរបស់ជនជាប់ឃុំឃាំង គឺមិនមានលទ្ធភាពការពារខ្លួន ហើយងាយនឹងទទួលរងការរំលោភបំពាន"[69]។

៣៨. អង្គជំនុំជម្រះសាលាដំបូងក៏បានរៀបរាប់ផងដែរពីសារៈសំខាន់នៃមន្ទីរស-២១ចំពោះបក្សកុម្មុយនីស្តកម្ពុជា ("បកក") ហើយតើឧក្រិដ្ឋកម្មនៅមន្ទីរស-២១ដែលធ្វើឱ្យញ័ររញ្ជួយនៅពាសពេញទូទាំងប្រទេសកម្ពុជានោះ មានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អះអាងថា "មន្ទីរស-២១ គឺជាមណ្ឌលសន្តិសុខមួយដ៏សំខាន់ខ្លាំងណាស់របស់កម្ពុជាប្រជាធិបតេយ្យ" និងថា ជនជាប់ចោទដែលជាប្រធាននៃមន្ទីរនេះ បានធ្វើរបាយការណ៍ជូនទៅ " មេដឹកនាំ បកក ថ្នាក់ខ្ពស់ជាងគេបំផុត"[70]។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូងរកឃើញបន្ថែមទៀតថា មន្ទីរស-២១ ត្រូវបានចាត់ទុកថាសំខាន់ជាអាយុជីវិតនៅក្នុងការសម្រេចឱ្យបាននូវគោលដៅនយោបាយរបស់ បកក និងក្នុងការអនុវត្តនូវគោលនយោបាយ "កំទេច"ខ្មាំង[71] របស់ បកក។ ថាចម្លើយសារភាពទាំងឡាយដែលមន្ទីរស-២១ស្រង់បានត្រូវបានគេយកទៅប្រើ ដើម្បីធ្វើការសម្រេចក្នុងការចាប់ខ្លួនជនទាំងឡាយដែលត្រូវបានបកអាក្រាតថា ជាភ្នាក់ងារខ្មាំង[72]។ ហើយថា "ពួកអ្នកដែលត្រូវគេឃុំឃាំងនៅក្នុងមន្ទីរស-២១ គឺត្រូវបានគេចាប់បញ្ជូនមកពីគ្រប់ទិសទីទាំងអស់នៃផ្ទៃប្រទេស និងពីគ្រប់តំបន់ទាំងអស់នៃសង្គមកម្ពុជា"[73]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានកត់សំគាល់ផងដែរថា "តួនាទីមួយក្នុងចំណោមតួនាទីផ្សេងៗទៀត របស់មន្ទីរ ស២១ ដែលបានកំណត់

---

[69] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៦០៥។

[70] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២៥។

[71] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៣២៨។

[72] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៧៩។

[73] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៣២៣។

អោយអនុវត្តនៅក្នុងការគ្រប់គ្រងសន្តិបាល គឺការសួរចម្លើយ និងសម្លាប់កម្មាភិបាលជាន់ខ្ពស់របស់បកក[74]។

៣៩. ស្រដៀងគ្នានេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញភស្តុតាងជាច្រើនទាក់ទងនឹងការចូលរួមយ៉ាងពេញទំហឹងរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អះអាងថា ក្នុងនាមជាប្រធាននៃមន្ទីរស-២១ ជនជាប់ចោទបានត្រួតពិនិត្យមើលពីលើ "កិច្ចប្រតិបត្តិការការងារនៃមន្ទីរស-២១ ទាំងមូលដែលក្នុងនោះរួមទាំងការធ្វើចំណារលើចម្លើយសារភាពព្រមទាំងការបញ្ជាឲ្យសម្លាប់ផង"[75]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ជនជាប់ចោទបាន " ដឹកនាំអង្គភាពសួរចម្លើយ" នៃមន្ទីរស-២១។ "បានចូលរួមនៅក្នុងការរៀបចំផែនការការងាររបស់មន្ទីរស-២១ និងនៅក្នុងការហ្វឹកហាត់ដល់បុគ្គលិកអំពីបច្ចេកទេសក្នុងការសួរចម្លើយ"[76] និងបាន "ពិនិត្យមើលឡើងវិញលើចម្លើយសារភាពរបស់ជនជាប់ឃុំឃាំង និងផ្តល់ការណែនាំជាបន្តបន្ទាប់ដល់អ្នកសួរចម្លើយ"[77]។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញថែមទៀតដែរថា "ជនជាប់ចោទបានពិនិត្យមើល និងបញ្ជូនបន្តទៅអោយថ្នាក់លើរបស់គាត់នូវចម្លើយសារភាពរបស់ជនជាប់ឃុំ និងបញ្ជីឈ្មោះ "ជនក្បត់" ដែលជា

---

[74] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២១១។

[75] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២៥។

[76] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២៥។ *សូមអានផងដែរ ដូចគ្នានឹងខាងលើ* កថាខណ្ឌទី១៧៦, ១៨១ (ដែលរកឃើញភស្តុតាងថា "ជនជាប់ចោទបានពិនិត្យមើលចម្លើយសារភាពរបស់ជនជាប់ឃុំឃាំងនានាឡើងវិញ និងបានផ្តល់នូវការណែនាំជាបន្តបន្ទាប់ដល់ពួកអ្នកសួរចម្លើយ" និងថា "ជនជាប់ចោទបានទទួចឲ្យទទួលស្គាល់ដោយផ្ទាល់ថា ការសួរចម្លើយត្រូវបានបំពេញចប់សព្វគ្រប់អស់ហើយនៅមុនពេលជនជាប់ឃុំឃាំងណាម្នាក់អាចធ្វើការប្រហារជីវិតបាន"។

[77] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៨១ ។

បញ្ជីប្រើសម្រាប់ការផ្តល់ដំណឹង និងសម្រួលដល់ការចាប់ខ្លួនមនុស្សជាបន្តបន្ទាប់ទៀត"[78]។ ជាងនេះទៅទៀត ថ្វីបើអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ថ្នាក់លើទាំងឡាយរបស់ជនជាប់ចោទជាទូទៅ គឺជាអ្នកធ្វើសេចក្តីសម្រេចស្តីពីថាតើអ្នកណាខ្លះដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១នោះក្តី[79] ក៏អង្គជំនុំជម្រះបានកត់សំគាល់ថា "មានភស្តុតាងបញ្ជាក់ថាជនជាប់ចោទដើរតួនាទីយ៉ាងសកម្មក្នុងការរៀបចំអោយមានការចាប់ខ្លួនលើកដំបូង ហើយមតិយោបល់របស់គាត់ត្រូវបានថ្នាក់លើរបស់គាត់អនុវត្តតាម"[80]។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញដែរថា"ជនជាប់ចោទបានធ្វើការដោយមិនខ្លាចនឿយហត់ដើម្បីធានាថា មន្ទីរស-២១ ដំណើរការប្រកបដោយប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន"[81] និងថាទោះបីជាគាត់បានធ្វើដូច្នេះដើម្បីបង្ហាញពីភក្តីភាពដ៏មោះមុតចំពោះថ្នាក់លើរបស់គាត់ និងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា"[82] ក៏ដោយក៏គាត់បានអនុវត្តនូវឧក្រិដ្ឋកម្មផ្សេងៗរបស់គាត់ ដោយចេតនារើសអើងយ៉ាងជាក់លាក់មួយ[83] ហើយសកម្មភាពរបស់គាត់ត្រូវបានប្រព្រឹត្ត "ដោយមិនបានគិតអំពីភាពជាមនុស្សរបស់អ្នកជាប់ឃុំទាំងឡាយដែលគាត់បានមើលការខុសត្រូវនោះឡើយ"[84]។

៤០. ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទនៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យនោះវិញ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញភស្តុតាងជាច្រើនដែលបង្ហាញថា គាត់មានអ្នកនៅក្រោមបង្គាប់

---

[78] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៧៣។
[79] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៦៨។
[80] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៦៩។
[81] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៥៩៧។
[82] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៥៩៧។
[83] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៦០៥។
[84] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី៥៩៧។

មួយចំនួនដែលត្រូវរាយការណ៍ជូនគាត់ និងមានឋានានុក្រមនៃលំដាប់ថ្នាក់តិចតួចតែប៉ុណ្ណោះនៅពីលើគាត់។ ឧទាហរណ៍ដូចជា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញភស្តុតាងថា ជនជាប់ចោទមាន "សិទ្ធិអំណាចពេញលេញទៅលើបុគ្គលិកទាំងអស់នៃមន្ទីរស-២១"[85] ដែលមានចំនួន ២.៣២៧ នាក់ នៅក្នុងខែមីនា ឆ្នាំ១៩៧៧[86] ដែលគាត់ "បានរៀបចំមន្ទីរស-២១ តាមឋានានុក្រម និងបានបង្កើតប្រព័ន្ធនៃការរាយការណ៍គ្រប់ជាន់ថ្នាក់ ដើម្បីធានាថារាល់បទបញ្ជារបស់គាត់ពិតជាត្រូវបានអនុវត្តភ្លាមៗ និងជាក់លាក់"[87] ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញភស្តុតាងជាច្រើនទៀតថាជនជាប់ចោទ បានរាយការណ៍ដោយផ្ទាល់ជូនសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍[88] ហើយថាមានភស្តុតាងថា យោបល់យល់ឃើញរបស់ជនជាប់ចោទទាក់ទងអំពីថាតើគួរចាប់ខ្លួនអ្នកណាខ្លះនោះ "ត្រូវបានថ្នាក់លើរបស់គាត់យកមកអនុវត្តតាម"[89]។ អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សំគាល់ផងដែរថាជនជាប់ចោទមាន "ឥទ្ធិពលយ៉ាងខ្លាំងទៅលើការចាប់ខ្លួនបុគ្គលិកមន្ទីរស-២១នេះ"[90]។

៤១. អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា ចំពោះស្មោះភាព និងភាពអចិន្ត្រៃយ៍នៃតួនាទីរបស់ជនជាប់ចោទនៅក្នុងទូទាំងអម្លុងពេលជាងបីឆ្នាំ ជាការបង្ហាញឲ្យឃើញថែមទៀតអំពីភាពសមហេតុសមផល នៃការរកឃើញរបស់ខ្លួនដែលថាជនជាប់ចោទ គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ក្នុងចំណោម "អ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។ អង្គជំនុំជម្រះសាលាដំបូង

---

[85] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៣២។

[86] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២០០។ ជនជាប់ចោទបានបញ្ជាក់អំពីចំនួននេះ។ *ដូចគ្នានឹងខាងលើ*។

[87] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៤៤។

[88] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៣១, ៣២៨។

[89] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៦៩។

[90] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៧១។

កត់សំគាល់ថា ជនជាប់ចោទបានទទួលសារភាពថា សុន សេន បានតែងតាំងគាត់ជាអនុប្រធានទទួលបន្ទុកអង្គភាពសួរចម្លើយនៅមន្ទីរស-២១ ក្នុងខែសីហា ឆ្នាំ១៩៧៥[91] ហើយថា គាត់បានក្លាយទៅជាប្រធាននៃមន្ទីរស-២១ ត្រឹមខែមីនា ឆ្នាំ១៩៧៦[92] និងបានត្រួតមើលពីលើមន្ទីរស-២១ រហូតមកទល់នឹងថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[93]។

៤២. សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ជនជាប់ចោទបានចាត់ចូលទៅក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់ក្នុងចំណោម "អ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" គឺមានលក្ខណៈស្របគ្នាផងដែរទៅនឹងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិដែលតុលាការបានបកស្រាយពាក្យពេចន៍ ដែលគេប្រើក្នុងន័យកំរិតកំណត់វិសាលភាពនៃការចោទប្រកាន់នៅអន្តរជាតិ។ ឧទាហរណ៍ដូចជា ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការ ICTY ដែលបានរកឃើញថា ចំណាត់ថ្នាក់មនុស្ស ដែលគ្របដណ្តប់ដោយពាក្យដ៏មានន័យចង្អៀតជាងនេះ- "មេដឹកនាំជាន់ខ្ពស់ជាងគេបំផុតដែលជាប់សង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត"[94]-គឺមិនកំរិតន័យតែត្រឹមជនទាំងឡាយដែលជា "ស្ថាបត្យករ" នៃគោលនយោបាយទាំងមូលដែលបង្កើតបានជាមូលដ្ឋាននៃឧក្រិដ្ឋកម្មនានាដែលត្រូវចោទប្រកាន់នោះទេ[95]។ ស្រដៀងគ្នានេះ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន បានធ្វើការបកស្រាយពាក្យពេចន៍ដែលមានន័យកាន់តែចង្អៀតជាងមាត្រា១ និងមាត្រា២ នៃច្បាប់ អវតក និងកិច្ចព្រមព្រៀងបង្កើត អវតក ទៅទៀត គឺក្នុងលក្ខណៈមួយដែលធ្វើ

---

[91] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១១៩-១២០។

[92] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី១៣០។

[93] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២០៣។

[94] សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Dragomir Milošević*, កថាខណ្ឌទី២។

[95] សេចក្តីសំរេចស្តីពីការបញ្ជូនសំណុំរឿងរបស់ *Dragomir Milošević*, កថាខណ្ឌទី២២។

ឲ្យកាន់តែមានភាពច្បាស់លាស់ដែលរួមបញ្ចូលនូវបុគ្គលនៅក្នុងប្រភេទ ដូចជាជនជាប់ចោទនេះដែរ។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") ចែងអំពីការចោទប្រកាន់"ជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវខ្ពស់ជាងគេបំផុត"[96]។ ពាក្យនេះត្រូវបានគេយល់ឃើញថា គ្របដណ្តប់ទៅលើក្រុមមនុស្សមួយក្រុម ដែលគេកំរិតកំណត់ខ្លាំងជាងអ្វីដែលគួរត្រូវបានគ្របដណ្តប់ដោយឃ្លា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ទៅទៀត[97]។ ថ្វីត្បិតតែអង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ SCSL បានកំណត់សម្រេចជាយថាហេតុថា ពាក្យ "ការទទួលខុសត្រូវខ្ពស់ជាងគេបំផុត" គឺជាមគ្គុទេសក៍នាំផ្លូវទៅកាន់ឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ហើយដែលមិនត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យឡើងវិញរបស់តុលាការ[98] នោះក្តីក៏គោលគំនិតនៃវិសាលភាពរបស់ពាក្យនេះអាចឃើញមាននៅក្នុងសេចក្តីសម្រេចមួយពីមុនមក របស់អង្គជំនុំជម្រះសាលាដំបូងទីII ដែលនៅតុលាការនេះបានបកស្រាយបញ្ញត្តិនេះថាគ្របដណ្តប់ទៅលើ "មនុស្សមួយក្រុមដែលគេរៀបចំតាមលំដាប់ពីមេដឹកនាំយោធា និងនយោបាយ *ចុះមកក្រោមរហូតដល់មនុស្សវ័យក្មេងអាយុ១៥ឆ្នាំ*"[99]។

---

[96] សូមអាន កិច្ចព្រមព្រៀងស្តីពីការបង្កើតតុលាការពិសេស, មាត្រា១ ។ លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលជាឧបសម្ព័ន្ធភ្ជាប់ជាមួយ *កិច្ចព្រមព្រៀងរវាង អសបនិងរដ្ឋាភិបាលនៃប្រទេសសៀរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន អង្គការសហប្រជាជាតិនិងប្រទេសសៀរ៉ាឡេអូន* ចុះថ្ងៃទី១៦ មករា ២០០២, 2178 U.N.T.S. 138 ["លក្ខន្តិកៈតុលាការសៀរ៉ាឡេអូន "] មាត្រា១.១។

[97] *សូមអាន ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Brima* , ដីកាសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីសុំឲ្យចេញដីកាលើកលែងទោស អនុលោមតាមវិធាន៩៨ , សំណុំរឿង លេខ SCSL-04-16-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL, ចុះថ្ងៃទី ៣១ មីនា ២០០៦ [*ដែលជាបន្តមកទៀតនៅក្នុងនេះហៅកាត់ថា"* ដីកាសម្រេចករណី Brima អនុលោមតាមវិធាន៩៨ "] , កថាខណ្ឌទី៣២(ដែលនិយាយថា រូបមន្តស្តីពី "អ្នកទទួលខុសត្រូវខ្ពស់បំផុត " ដែលបានស្នើយោបល់ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានច្រានចោលដោយក្រុមប្រឹក្សាសន្តិសុខ ដែលទទូចសុំឲ្យកំរិត រូបមន្ត "អ្នកទទួលខុសត្រូវធំជាងគេបំផុត"ឲ្យចង្អៀតជាងនេះ]។

[98] *សូមអាន* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Brima, កថាខណ្ឌទី២៨០-២៨៤។

[99] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Brima* , សាលក្រម, សំណុំរឿង លេខ SCSL-04-16-T, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL, ចុះថ្ងៃទី ២០ មិថុនា ២០០៧ [*ដែលជាបន្តមកទៀតនៅក្នុងនេះហៅកាត់ថា"* សាលក្រមសាលាដំបូងលើករណី *Brima* "],

៤៣. វាក៏ជាការច្បាស់លាស់ណាស់ ចាប់តាំងពីប្រវត្តិនៃការធ្វើសេចក្តីព្រាងឯកសារផ្សេងៗ ដើម្បីបង្កើត អវតក មកគឺថាពាក្យពេចន៍នៅក្នុងមាត្រា១ និងមាត្រា២នៃច្បាប់ អវតក និងកិច្ចព្រមព្រៀងស្តីពីការបង្កើត អវតក គឺមានបំណងគ្របដណ្តប់ទៅលើជនទាំងឡាយ ដែលស្ថិតនៅក្នុងតួនាទីដូចជាតួនាទីដែលបានកាន់កាប់ដោយដើមបណ្តឹងសាទុក្ខនេះ។ តាមពិតទៅ គឺក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានលើកឡើងយ៉ាងច្បាស់សំដៅ "មន្ត្រីផ្លូវការទាំងឡាយនៃមណ្ឌលធ្វើទារុណកម្ម និងសួរចម្លើយ តួយ៉ាងដូចជាទួលស្លែងជាដើម" ធ្វើជាឧទាហរណ៍អំពីប្រភេទនៃជនទាំងឡាយដែល អវតក គួរត្រូវបានផ្តល់អំណាច ដើម្បីធ្វើការវិនិច្ឆ័យទោស[100]។

៤៤. លើសពីនេះ ទោះបីជាដើមបណ្តឹងសាទុក្ខបានពោលអះអាងថា មិនអាចត្រូវចាត់បញ្ចូលគាត់ជា "អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត"បានទេ ព្រោះដោយសារអតីតប្រធានពន្ធនាគារនានាមិនត្រូវបានយកមកកាត់ទោសនោះឡើយ[101] ការតវ៉ានេះគឺមិនមានមូលដ្ឋានត្រឹមត្រូវឡើយ- ដោយសារអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា កិច្ចព្រមព្រៀងបង្កើត អវតក និងច្បាប់ អវតក គ្មានតម្រូវកាតព្វកិច្ចណាមួយដើម្បីឲ្យត្រូវតែធ្វើការជំនុំជម្រះក្តីលើរាល់ចារីដែលមានសក្តានុពលគ្រប់ទាំងអស់

---

កថាខណ្ឌទី៦៥៨-៦៥៩ (ដែលសង្កត់ន័យដោយអក្សរទ្រេត)។ *សូមអានផងដែរ ករណីរឿក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង* Brima , ដីកាសម្រេចអនុលោមតាមវិធាន៩៨ , កថាខណ្ឌទី ៣៤-៣៥ (ដែលនិយាយថា ពាក្យពេចន៍ដែលគេប្រើថា "ជនទាំងឡាយដែលត្រូវទទួលខុសត្រូវធំជាងគេបំផុត" គឺគ្មានអ្វីក្រៅពីត្រូវបានកំរិតកំណត់ត្រឹមតែពួកមេដឹកនាំខាងនយោបាយនិងយោធាតែប៉ុណ្ណោះ និងថាអាចនឹងមានជនដទៃទៀតដែលអាចនឹងចាត់ចូលនៅក្នុងប្រភេទជនទាំងនេះដែរ)។ *ដូចគ្នានឹងខាងលើដែរ,* កថាខណ្ឌទី៣៨ (ដែលហាក់ដូចជាស្នើយោបល់ថា ជនណាម្នាក់ដែលបាន "ជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ" ដែលគេអាចចាត់ចូលនៅក្នុងប្រភេទ " អ្នកទទួលខុសត្រូវធំជាងគេបំផុត") ។

[100] របាយការណ៍របស់ក្រុមអ្នកជំនាញនៃ អសប កថាខណ្ឌទី១០៩។ ជំហរនេះក៏ស្របគ្នាផងដែរជាមួយនឹងសេចក្តីអធិប្បាយផ្តល់មតិរបស់ឯកឧត្តម អេង រ៉ៃអៀង នៅក្នុងពេលប្រជុំពិភាក្សាច្បាប់របស់រដ្ឋសភា កាលពីថ្ងៃទី៤-៥ខែតុលា ឆ្នាំ២០០៤ ដែលសន្មត់ថា មានឆ្មាំយាមការពារសន្តិសុខនៅទួលស្លែងខ្លះគួរតែបានចាត់ចូលនៅក្នុងប្រភេទនៃជនទាំងឡាយដែលស្ថិតនៅក្នុងយុត្តាធិការនៃ អវតក។ ដោយសន្មតថាត្រូវបានចាត់ទុក ថា ជាក់ជាងនេះទៅទៀតដែលពាក្យពេចន៍ដែលប្រើថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"នៅក្នុងច្បាប់ អវតក គួររួមបញ្ចូលទាំងប្រធានគុកទួល ស្លែងផង ។ *សូមអាន* សម័យប្រជុំពិភាក្សានៃរដ្ឋសភា ឆ្នាំ២០០៤ ទំព័រ២៨-២៩។

[101] សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី, កថាខណ្ឌទី២៣។

នៃឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួននោះទេ[102]។ ដូចគ្នានឹងព្រះរាជអាជ្ញាអន្តរជាតិ ឬជាតិណាមួយផ្សេងទៀតដែរ សហព្រះរាជអាជ្ញានៅ អវតក ត្រូវបានរំពឹងទុកឱ្យធ្វើការជ្រើសរើសមួយអំពីថាតើជនជាប់សង្ស័យណាខ្លះ ដែលត្រូវនាំយកទៅជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃការពិនិត្យជាបឋមមួយលើអង្គហេតុដែលមានស្រាប់[103]។ ការអនុវត្តឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់មិនមែនជាការអនុវត្តផ្នែកគ្រឿងយន្តនោះទេ។ ផ្សេងពីនេះ គឺតម្រូវឱ្យធ្វើការថ្លឹងថ្លែងអំពីកត្តាផ្សេងៗ ដូចជា បរិមាណ និងគុណភាពនៃភស្តុតាងដែលមានស្រាប់ កំរិតនៃពិរុទ្ធភាពរបស់ជនល្មើស និងស្ថានទម្ងន់ទោសនៃឧក្រិដ្ឋកម្មទាំងនោះ និងអំពីភវនីយភាពក្នុងការឃុំខ្លួនជនល្មើស[104]។

---

[102] សាលក្រម សំណុំរឿងលេខ០០១, កថាខណ្ឌទី២៤ ។ ច្បាប់ អវតក ចែងថា អវតក មាន "អំណាច" វិនិច្ឆ័យទោសជនសង្ស័យដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការនៃតុលាការនេះ។ ប៉ុន្តែ ច្បាប់នេះមិនបានចែងថា អវតក មាន "កាតព្វកិច្ច" ត្រូវតែធ្វើដូច្នេះនោះឡើយ។ *សូមអាន* ច្បាប់ អវតក ពីមាត្រា៣ថ្មី ដល់ មាត្រា៨។

[103] គោលការណ៍ស្តីពីឆន្ទានុសិទ្ធិក្នុងការវិនិច្ឆ័យទោស គឺត្រូវបានរួមបញ្ចូលនៅក្នុងឯកសារនានាស្តីពីការបង្កើត និងនៅក្នុងវិធានផ្ទៃក្នុងនៃ អវតក ហើយ។ *សូមអានឧទាហរណ៍ដូចជា* ច្បាប់អវតក, មាត្រា១៦ (រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅ អវតក គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់..........ដែលត្រូវធ្វើការរួមគ្នាដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជនសង្ស័យសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ)។ កិច្ចព្រមព្រៀង អវតក, មាត្រា៦ (បានចែងថា "សហព្រះរាជអាជ្ញា ... ទទួលខុសត្រូវលើការងារចោទប្រកាន់") និងថាសហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬ ស្វែងរកការណែនាំពីរដ្ឋាភិបាលឬប្រភពណាមួយផ្សេងទៀតឡើយ")។ វិធាន៤៩.១ ("ការចោទប្រកាន់បទឧក្រិដ្ឋទាំងឡាយណាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក អាចធ្វើឡើងបានតាមការផ្តួចផ្តើមគំនិតរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសម្រេចចិត្តដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹងក៏ដោយ")។ វិធាន៥០.១ (" សហព្រះរាជអាជ្ញាអាចដឹកនាំការស៊ើបអង្កេតបឋម... ដើម្បីកំនត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីសំខាន់ៗ")។ វិធាន៥៥.២ (ចែងថាសហចៅក្រមស៊ើបអង្កេតត្រូវស៊ើបសួរតែអង្គហេតុណាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម)។ វិធាន៥៥.៤ (ចែងថា សហចៅក្រមស៊ើបអង្កេតមានអំណាចបើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយណាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបន្ទាប់ពីសួរយោបល់សហព្រះរាជអាជ្ញា)។ សូមអាន ផងដែរ កិច្ចប្រជុំពិភាក្សានៃរដ្ឋសភាឆ្នាំ២០០៤ (ឯ.ឧ. សុខ អាន), ទំព័រ២៩ (ដែលបញ្ជាក់ថា ការជ្រើសរើសជនជាប់ចោទដើម្បីធ្វើការជំនុំជម្រះគឺជា "ភារកិច្ចរបស់សហព្រះរាជអាជ្ញា") ។

[104] *សូមអាន ជាទូទៅ* អត្ថបទរបស់លោក John Ralston និង Sarah Finnin dEl, *ការស៊ើបអង្កេតលើឧក្រិដ្ឋកម្មអន្តរជាតិនានា: ការពិនិត្យឡើងវិញទៅលើយុទ្ធសាស្ត្រក្នុងការពង្រឹងការប្រតិបត្តិច្បាប់អន្តរជាតិ* ដែលមាននៅក្នុង សៀវភៅរបស់លោក DAVI A. BLUMENTHAL, TIMOTHY L.H. McCORMACK ដែលមានចំណងជើងថា **កេរ្តិ៍ដំណែលរបស់នូរ៉ាំប៊ឺហ្គ៖ ឥទ្ធិពលដែលមានអារ្យធម៌ឬការធ្វើឱ្យអំពើហិង្សាមានលក្ខណៈជាស្ថាប័ន?** (ឆ្នាំ២០០៨), ទំព័រ៥០ (ដែលពិភាក្សាអំពីលក្ខណៈវិនិច្ឆ័យមួយចំនួនដែលបានប្រើប្រាស់ដោយរដ្ឋអាជ្ញាសម្រាប់ជាមាត៌

៤៥. លើសពីនេះទៀត ការលើកឡើងរបស់ដើមបណ្តឹងសាទុក្ខ ពីមាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា មិនបានផ្តល់នូវការគាំទ្រណាមួយ ចំពោះគោលជំហររបស់ខ្លួនឡើយ[105]។ ទ្រឹស្តីអំពីសមភាពនៅចំពោះមុខច្បាប់-ដូចដែលមានជាភស្តុតាងនៅក្នុងខ្លឹមសារនៃមាត្រា៣១- គឺយោងទៅដល់សញ្ញាណដែលថា ជនគ្រប់រូបទាំងអស់ត្រូវឋិតនៅក្រោមច្បាប់ដូចគ្នា ដោយមិនគិតពីពូជសាសន៍ ធនធាន ភេទ ឬចំណាត់ថ្នាក់នៃស្ថានភាពឯទៀតរបស់ពួកគេឡើយ[106]។ គោលការណ៍នេះបានការពារមិនឱ្យមានការចោទប្រកាន់ដែលជ្រើសរើស ដោយមានមូលដ្ឋាននៅលើមូលហេតុរើសអើង ដែលគេមិនអនុញ្ញាតឡើយ ក៏ប៉ុន្តែវាមិនមានន័យថា បុគ្គលម្នាក់អាចត្រូវគេធ្វើការចោទប្រកាន់ បានលុះត្រាណាតែអ្នកដទៃទៀតទាំងអស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រភេទដូចគ្នា ក៏ត្រូវបានគេធ្វើការចោទប្រកាន់ផងដែរ នោះឡើយ[107] ។

---

នាំផ្លូវដល់រដ្ឋអាជ្ញានៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិ)។ *សូមអានផងដែរ ដូចគ្នានឹងខាងលើ* , ទំព័រ៤៩ (ដែលកត់សំគាល់ថា "[] ការរួមបញ្ចូលគ្នានៃការកំរិតសមត្ថភាពជាពិសេសរបស់ប្រព័ន្ធអន្តរជាតិ និងការប្តេជ្ញាចិត្តរបស់ប្រព័ន្ធនេះចំពោះការទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល ... គឺមានន័យថា រដ្ឋអាជ្ញាអន្តរជាតិតាមការចាំបាច់ត្រូវតែធ្វើការសម្រិតសម្រាំងដោយប្រុងប្រយ័ត្នក្នុងការប្តេជ្ញាអំពីធនធានសម្រាប់ធ្វើការស៊ើបអង្កេតនិងចោទប្រកាន់អំពីឧក្រិដ្ឋកម្មពិសេសមួយចំនួន...[រដ្ឋអាជ្ញា] ដូចគ្នានឹងដៃគូនានាក្នុងស្រុកដែរ ត្រូវតែបង្កើតឡើងនូវយុទ្ធសាស្រ្តផ្សេងៗសម្រាប់ផ្តោតធនធានផ្សេងៗរបស់ខ្លួនទៅលើការចោទប្រកាន់ទាំងឡាយណាដែលខ្លួនយល់ឃើញថាសំខាន់")។

[105] សូមមើល, សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៣៩ ។

[106] នៅក្នុងផ្នែកពាក់ព័ន្ធនេះ មាត្រា៣១ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ចែងថា៖ "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ" ។ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៣១ ។

[107] *សូមមើល* Hassan B. Jallow, *Prosecutorial Discretion and International Criminal Justice*, 3 J. Crim. Int'l Just.145, 159-160 (2005)(ដោយបានរៀបរាប់អំពីបទដ្ឋានដាច់ខាតក្នុងការបង្កើតជាការចោទប្រកាន់មួយដ៏ជាក់លាក់ដែលឆ្លុះបញ្ចាំងពីការបំពានលើឆន្ទានុសិទ្ធិរបស់រដ្ឋអាជ្ញា និងដោយបានពន្យល់ថា៖ "ដោយគ្រាន់តែការបង្កើតឱ្យមានការដាក់បុគ្គលតាំងនៅ ដែលមិនមែនជាការដែល ត្រូវបានចោទប្រកាន់នោះ" គឺមិនបានបង្ហាញពីការរំលោភលើគោលការណ៍សមភាពនៅចំពោះមុខច្បាប់នោះទេ)។ ការលើកឡើងរបស់ដើមបណ្តឹងសាទុក្ខ អំពីមាត្រា ១៤.១ នៃអនុសញ្ញា ICCPR ត្រង់កថាខណ្ឌទី ៦៥ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺមិនជំពាក់ទាក់ទងដូចតែគ្នាទេ។ *សូមមើល* United Nations Human Rights Committee, General Comment No. 32, មាត្រា១៤ ៖ សិទ្ធិស្តីពី សមភាពនៅចំពោះមុខតុលាការ និងអង្គជំនុំជម្រះ និងសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីមួយដ៏ត្រឹមត្រូវ, U.N. Doc. CCPR/C/GC/ 32 (2007), ផ្នែកទី II (ដោយមិនបានពោលដល់ទំនាស់ណាមួយរវាងទស្សនៈស្តីពីឆន្ទានុសិទ្ធិរបស់រដ្ឋអាជ្ញា ហើយមាត្រា១៤ បានធានាអំពី "សមភាពនៅចំពោះមុខ តុលាការ និងអង្គជំនុំជម្រះ" និងការបកស្រាយឃ្លានោះថាជាការធានា ទី១) គ្រប់បុគ្គល

៤៦. ក្នុងករណីណាក៏ដោយ ខណៈដែលដើមបណ្តឹងសាទុក្ខព្យាយាមសន្និដ្ឋានខ្លួនឯងថាគ្រាន់តែជាមេដឹកនាំមន្ទីរសន្តិសុខម្នាក់ក្នុងចំណោមមេដឹកនាំមន្ទីរសន្តិសុខជាច្រើន[108] ក៏នៅមានភស្តុតាងដែលបានបង្ហាញនៅពេលសវនាការ គឺមិនបានគាំទ្រដល់សេចក្តីសន្និដ្ឋាននេះឡើយ។ តាមពិតទៅ អ្នកជំនាញដូចគ្នា ដែលដើមបណ្តឹងសាទុក្ខបានយោងនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនោះ[109] ក៏បានផ្តល់សក្ខីកម្មផងដែរថា មន្ទីស-២១ គឺមានលក្ខណៈ "ទោល នៅក្នុងចំណោមមន្ទីរសន្តិសុខទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យ" ពីព្រោះ ទី១) វាជាមន្ទីរសន្តិសុខ ដែលត្រូវបានចាត់តាំងឱ្យកំទេចមនុស្សនៅលំដាប់ថ្នាក់មជ្ឈិម ដោយរួមទាំង បុគ្គលលំដាប់ថ្នាក់ខ្ពស់បំផុតនានានៃបក្សកុម្មុយនីស្តកម្ពុជាផង ទី២) វាជាមន្ទីរសន្តិសុខតែមួយគត់ដែលត្រូវបានអនុញ្ញាតឱ្យឃុំខ្លួន ធ្វើទារុណកម្ម និងប្រហារជីវិតបុគ្គលនានាដែលមកពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា និងទី៣) វាឋិតនៅក្នុងប្រភេទមួយដោយខ្លួនវាផ្ទាល់ ពាក់ព័ន្ធនឹងទំហំនៃចំនួនបុគ្គលិករបស់វា ដោយប្រៀបធៀបទៅនឹងមន្ទីរសន្តិសុខផ្សេងៗទៀត[110]។ ស្រដៀងគ្នានេះដែរ អ្នកជំនាញរូបនេះបានផ្តល់សក្ខីកម្ម

---

ទាំងអស់ត្រូវមានតុលាការ ដោយស្មើភាពគ្នា ដោយមិនមានការរើសអើង, ទី២) ចុងចោទព្រហ្មទណ្ឌទាំងអស់ ត្រូវបានធ្វើការចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះ មួយដែលបង្កើតឡើងដោយច្បាប់ ដែលមានសមត្ថភាព ឯករាជ្យ និងមិនលំអៀងពេញលេញ, និងទី៣) គ្រប់បុគ្គលទាំងអស់មានសិទ្ធិដូចៗគ្នា ទៅតាមនីតិវិធី លើកលែងតែមានការខុសគ្នាដែលមានមូលដ្ឋាននៅលើច្បាប់ និងដែលអាចត្រូវបានធ្វើយុត្តិកម្មតាមទឡ្ហីករណ៍សត្យានុម័ត និង ដោយសមហេតុសមផល) ។

[108] សូមមើល, សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ២១, ២៥ ។

[109] សូមមើល, សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៦៦, ៧១, ៧២-៨៦ (ដោយបានលើកឡើងពីរបាយការណ៍របស់លោក Craig Etcheson, អ្នកជំនាញការ) ។

[110] ប្រតិចារិកសវនាការអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៧ ឧសភា ២០០៩, សក្ខីកម្មរបស់លោក Craig Etcheson, T.69-71 ។ *សូមមើលផងដែរ ដូចគ្នាដែល* ត្រង់ទំព័រទី ៧៤ (ដោយបានពោលថា ជាច្រើនបែបយ៉ាង មន្ទីរស-២១ មានលក្ខណៈទោលក្នុងចំណោមមន្ទីរសន្តិសុខនានា ដោយសារតែ "មុខងារទោលរបស់វា និងមានអាទិភាពខ្ពស់ណាស់ក្នុងការដាក់ពួកមេដឹកនាំបដិវត្តកំពូលៗនៅក្នុងនោះ") ។ *ដូចគ្នាដែល* ទំព័រទី ៧៥ ("មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខតែមួយប៉ុណ្ណោះរបស់រដ្ឋាភិបាលមជ្ឈិម") ។ ប្រតិចារិកសវនាការអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៨ ឧសភា ២០០៩, សក្ខីកម្មរបស់លោក Craig Etcheson, T.15 ("នីតិវិធីក្នុងការសួរចម្លើយ និងបង្កើតនូវចម្លើយសារភាពនៅមន្ទីរស-២១ គឺមានលក្ខណៈពិស្តារ ល្អិតល្អន់ និងហ្មត់ចត់ជាងនីតិវិធីក្នុងការសួរចម្លើយ និងបង្កើតនូវចម្លើយសារភាពនៅតាមមន្ទីរសន្តិសុខនានា ដែលខ្ញុំបានដឹង") ។

ថា គាត់ជឿជាក់ថាដើមបណ្តឹងសាទុក្ខរូបនេះគឺខុសគ្នាពីប្រធានមន្ទីរសន្តិសុខដទៃទៀត ពីព្រោះ ទី១) គាត់តែម្នាក់ឯង មានតំបន់ប្រតិបត្តិការនៅទូទាំងប្រទេស ទី២) គាត់តែម្នាក់ឯងបានរាយការណ៍ជូនទៅគ្រប់លំដាប់ថ្នាក់ដឹកនាំខ្ពស់បំផុតនីមួយៗ នៅក្នុង បកក ជាប្រចាំថ្ងៃ និងជាញឹកញាប់ដោយផ្ទាល់ខ្លួនទៀតផង និងទី៣) ពីព្រោះគាត់ទទួលខុសត្រូវលើមន្ទីរសន្តិសុខមួយដែលមានទំហំជារូបវន្តមួយរវាងពី ៥០-២០០ដង ធំជាងមន្ទីរសន្តិសុខដទៃទៀតទាំងអស់[111]។

៤៧. ហេតុដូច្នេះ ដោយមានមូលហេតុទាំងអស់ដូចបានជម្រាបមកខាងដើមនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វាមិនមានកំហុសទេ ដែលអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តនូវយុត្តាធិការបុគ្គលទៅលើដើមបណ្តឹងសាទុក្ខរូបនេះ។

## ៣. ចម្លើយតបទៅនឹងបណ្តឹងករណីទី២ៈ អង្គជំនុំជម្រះសាលាដំបូងមិនមានការភាន់ច្រឡំ "ចំពោះការផ្តន្ទាទោស"

[111] ប្រតិចារិកសវនាការអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី២៨ ឧសភា ២០០៩, សក្ខីកម្មរបស់លោក Craig Etcheson, T.46-47 ។ នៅខណៈដែលបានរក្សា(ជំហរដដែល)ថាមន្ទីរស-២១ មិនមានឋានានុក្រមជាថ្នាក់លើទេ នោះជំនាញការផ្ទាល់របស់មេធាវីការពារក្តីបានយល់ស្របតាមថា ចរិកលក្ខណៈទោលតែមួយគត់នៃមន្ទីរស-២១ នោះគឺការទទួលមនុស្សពីគ្រប់ទីកន្លែងក្នុងប្រទេស "ដែលត្រូវបានគណៈអចិន្ត្រៃយ៍របស់គណៈកម្មាធិការមជ្ឈិមបញ្ជូនទៅកាន់ទីនោះ" ។ ប្រតិចារិកសវនាការអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៤ កញ្ញា ២០០៩, សក្ខីកម្មរបស់លោក Raoul Marc Jenner, T.83, 94 ។ *សូមមើលផងដែរ* ប្រតិចារិកសវនាការអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី៦ សីហា ២០០៩, សក្ខីកម្មសវនាការរបស់លោក David Chandler, T.13-14 (ដោយបានពោលថា ព័ត៌មានដែល មានស្រាប់ដែលបញ្ជាក់ថាមន្ទីរស-២១ គឺ ខុសប្លែកពីគេក្នុងចំណោមមន្ទីរសន្តិសុខនានានោះ គឺថា គុកផ្សេងៗទៀតមិនមានចំណុះឯកសារដូចគ្នានេះទេ, មិនបានដាក់គុក ឬសួរចម្លើយ ជាប់ជាប្រចាំទៅលើពួកបុគ្គលថ្នាក់ខ្ពស់បំផុត ហើយនិងមិនត្រូវបានគ្រប់គ្រងដោយផ្ទាល់ពីសំណាក់មេដឹកនាំជាន់ខ្ពស់នោះទេ) ។

៤៨. រីឯទឡ្ហីករណ៍ទី២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះ សហមេធាវីការពារក្តីបានលើកឡើងចោទថាមាន “ការភាន់ច្រឡំចំពោះការផ្តន្ទាទោស”[112]។ ដោយឡែក សហមេធាវីការពារក្តីបានលើកឡើងចោទថា អង្គជំនុំជម្រះសាលាដំបូង “ខកខានមិនបានពិនិត្យមើលវិធាន ៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក ហើយសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី… ដែលនាំឱ្យភស្តុតាងដោះបន្ទុកមិនត្រូវបានគេយកមកពិនិត្យទាំងស្រុង ក្នុងការធ្វើឱ្យប្រាកដថា អវតក ពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទ មែនដែរឬទេ តាមការសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ”[113]។ ពួកគាត់បានលើកឡើងចោទបន្ថែមទៀតថា “អង្គជំនុំជម្រះប្រើប្រាស់សច្ចធារណ៍ហួសហេតុ ដោយពោលថា យល់ស្របតាមព្រះរាជអាជ្ញា ហើយមិនបានលើកសំអាងហេតុណាមួយមកធ្វើជាអំណះអំណាងគួរឱ្យជឿបានដោយគ្មានវិមតិសង្ស័យលើរាល់ភស្តុតាង ដែលខ្លួនបានប្រើប្រាស់ធ្វើជាសំអាងហេតុក្នុងការកំណត់អំពីយុត្តាធិការរបស់ខ្លួនលើជនជាប់ចោទ”[114]។

៤៩. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញា សន្និដ្ឋានថា៖ ទី១) ទឡ្ហីករណ៍ទី២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះ គឺមិនមែនជាទឡ្ហីករណ៍ដាច់ដោយឡែកនៃបណ្តឹងសាទុក្ខទេ ហើយគួរតែត្រូវបានបដិសេធចោល ដោយសារមូលហេតុដូចគ្នាទៅនឹងទឡ្ហីករណ៍ទី១ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី និងទី២) ដោយមានការផ្ទុយគ្នាទៅនឹងការអះអាងរបស់ដើមបណ្តឹងសាទុក្ខ គឺវា

---

[112] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, ទំព័រទី ១៩ (ចំណងជើង) ។ ដូចដែលបានពោលនៅក្នុងផ្នែកទី១ រួចហើយ ចំណាត់ថ្នាក់នៃទឡ្ហីករណ៍ទី២ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺខុសគ្នាពីចំណាត់ថ្នាក់នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលកាលពីពេលនោះបានដាក់បង្ហាញថា៖ “ការភាន់ច្រឡំចំពោះការផ្តន្ទាទោសដាក់ពន្ធនាគារសរុបរួមកំណត់ ៣៥ ឆ្នាំ” ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, ទំព័រទី ២ (ចំណងជើង) ។

[113] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៦៦ ។

[114] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៦៩ ។

មិនមានការចង្អុលបង្ហាញណាមួយ ដែលថាអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំ ដោយខកខានមិនបានពិចារណាទៅលើ "ភស្តុតាងដោះបន្ទុក"។

## ក. ទឡ្ហីករណ៍ទី២ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺមិនមែនជាទឡ្ហីករណ៍ដាច់ដោយឡែកនៃបណ្តឹងសាទុក្ខទេ ហើយគួរតែត្រូវបានបដិសេធចោលដោយសារមូលហេតុដូចគ្នាទៅនឹងទឡ្ហីករណ៍ទី១ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី

៥០. ដើមបណ្តឹងសារទុក្ខខកខានមិនបានបង្ហាញថាតើ "ទឡ្ហីករណ៍ទី១" និង "ទឡ្ហីករណ៍ទី២" នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះ បង្កើតបានជាទឡ្ហីករណ៍ដាច់ដោយឡែកពីគ្នាក្នុងបណ្តឹងសាទុក្ខនោះទេ។ ទោះបីជាទឡ្ហីករណ៍ទី១ ត្រូវបានពិពណ៌នាថាជាលើកឡើងចោទពី "ការភាន់ច្រឡំមួយពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល" ហើយទឡ្ហីករណ៍ទី២ ត្រូវបានលើកឡើងដើម្បីអោយចេញជា "ការភាន់ច្រឡំមួយពាក់ព័ន្ធនឹងការផ្តន្ទាទោស"ក៏ដោយ ក៏សេចក្តីសំអាងហេតុដែលបានដាក់ចំណោងជើងទឡ្ហីករណ៍ទាំងពីរ ត្រូវបានតាក់តែងឡើងដើម្បីបកស្រាយបង្ហាញពីការភាន់ច្រឡំ ដូចគ្នា តែមួយ- គឺអង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំមួយ នៅក្នុងការអនុវត្តនូវយុត្តាធិការបុគ្គលទៅលើដើមបណ្តឹងសាទុក្ខ។

៥១. តាមពិត ដើមបណ្តឹងសាទុក្ខមិនបានទាមទារឱ្យអង្គជំនុំជម្រះសាលាដំបូង លើកលែងការចោទប្រកាន់លើរូបគាត់តាមអង្គសេចក្តីដែលថា អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងត្រឹមត្រូវទៅលើភស្តុតាងជាក់លាក់នោះទេ។ ផ្ទុយទៅវិញ គាត់បានចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញថាមានយុត្តាធិការបុគ្គលទៅលើរូបគាត់ទេ បន្ទាប់ពីបានពិចារណាលើ

ភស្តុតាងបែបដូច្នោះរួចមក[115]។ និយាយម៉្យាងវិញទៀត ដើមបណ្តឹងសាទុក្ខបានលើកឡើងចោទ ថា មានការភាន់ច្រឡំមួយនៅក្នុងការកំណត់របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីយុត្តាធិការបុគ្គល ដែលជា <u>ការភាន់ច្រឡំដូចគ្នាតែមួយ</u> ដូចដែលបានលើកឡើងចោទនៅក្នុងទឡ្ហីករណ៍ទី១ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ ដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថាទឡ្ហីករណ៍ទី២ មិនអាចត្រូវបានមើលឃើញថាជាទឡ្ហីករណ៍ដាច់ៗពីគ្នានៃបណ្តឹងសាទុក្ខនោះទេ ហើយវាសមនឹងត្រូវបានពិចារណាថាជា សំអាងហេតុតូចមួយដែលឋិតនៅក្នុងទឡ្ហីករណ៍ទី១ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ ព្រោះហេតុនោះហើយ បានជាសេចក្តីសំអាងរបស់សហព្រះរាជអាជ្ញា ក្នុងការគាំទ្រដល់ការច្រានចោលនូវទឡ្ហីករណ៍ទី១នៃបណ្តឹងសាទុក្ខ បានអនុវត្តត្រូវគ្នាទៅនឹងទឡ្ហីករណ៍ទី២។

៥២. ក្នុងករណីណាក៏ដោយ ដោយមិនគិតអំពី ថាតើវាត្រូវបានគេចាត់ជាចំណាត់ថ្នាក់បែបណានោះទេ ទឡ្ហីករណ៍ទី២នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី គឺមិនអាចទទួលយកបានទេព្រោះថា ដូចដែលបានពិភាក្សានៅខាងលើស្រាប់ ដើមបណ្តឹងសាទុក្ខធ្លាប់បានបោះបង់សិទ្ធិរបស់ខ្លួនក្នុងការជំទាស់ទៅនឹងការអនុវត្តនូវយុត្តាធិការបុគ្គលទៅលើរូបគាត់រួចមកហើយ។ ដោយត្រឹមត្រូវសមហេតុផល ការបោះបង់សិទ្ធិបែបដូច្នេះ គឺវាហ៊ុមព័ទ្ធទៅលើការភាន់ច្រឡំណាមួយ ដែលបណ្តាលឱ្យមានការអនុវត្តដោយមិនត្រឹមត្រូវនូវយុត្តាធិការបុគ្គលទៅលើរូបគាត់។ ចំពោះបញ្ហានេះ គឺថាអង្គជំនុំ

---

[115] *សូមមើល, ឧទា.* សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៦៦ (ដោយបានលើកឡើងថា៖ "ភស្តុតាងដោះបន្ទុកមិនត្រូវបានគេយកមកពិនិត្យទាំងស្រុង ក្នុងការធ្វើឱ្យប្រាកដថា អ.វ.ត.ក ពិតជាគ្មានយុត្តាធិការលើបុគ្គលជនចាប់ចោទមែនដែរឬទេ") ។ *ដូចគ្នា ដដែល,* កថាខណ្ឌទី ៦៩ (ដោយបានលើកឡើងចោទថាអង្គជំនុំជម្រះសាលាដំបូង៖ "ខកខានមិនបានពិនិត្យមើលលើភស្តុតាងដោះបន្ទុកលើយុត្តាធិការបុគ្គលទាំងស្រុង") ។ *ដូចគ្នាដដែល,* កថាខណ្ឌទី ៧០ (ដោយបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងយល់ស្របតាមថាពិតជាគ្មានយុត្តាធិការលើបុគ្គលជនជាប់ចោទទេ បើសិនជាខ្លួន "បានពិនិត្យមើលភស្តុតាងតាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ") ។

ជម្រះតុលាការកំពូលមានសិទ្ធិអំណាចពិនិត្យលើកំហុសផ្នែកអង្គច្បាប់ ដែលធ្វើឱ្យ សាលក្រម *ទុកជាមោឃៈ* ប៉ុណ្ណោះ[116]។

## ខ. អង្គជំនុំជម្រះសាលាដំបូង មិនមានការភាន់ច្រឡំ ដោយខកខានមិនបានពិចារណាទៅលើ ភស្តុតាង "ដោះបន្ទុក" ទេ

៥៣. នៅក្នុងវិសាលភាពមួយដែលថាទឡ្ហីករណ៍ទី២ អាចញែកឱ្យដាច់ចេញពីទឡ្ហីករណ៍ទី១បាននោះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដើមបណ្ដឹងសាទុក្ខបានខកខានក្នុងការបង្ហាញពីការភាន់ច្រឡំមួយ នៅខាងផ្នែកនៃអង្គជំនុំជម្រះសាលាដំបូង។ ផ្ទុយពីការអះអាងរបស់ដើមបណ្ដឹងសាទុក្ខ គឺវាពុំមានការចង្អុលបញ្ជាក់ណាមួយដែលថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាទៅលើភស្តុតាងពាក់ព័ន្ធក្នុងការធ្វើឱ្យការរកឃើញរបស់ខ្លួនថាជាយុត្តាធិការបុគ្គល។ តាមពិតទៅ ការពិភាក្សារបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការទទួលខុសត្រូវរបស់ដើមបណ្ដឹងសាទុក្ខ នៅពេញទាំងសាលក្រមនេះ ហើយនិងភស្តុតាងនានា ដែលបានរៀបរាប់នៅទីនោះ បញ្ជាក់ពីភាពផ្ទុយគ្នាយ៉ាងច្បាស់។

៥៤. កំហុសជាសារវន្តនៅក្នុងការពិចារណារកហេតុផលរបស់ដើមបណ្ដឹងសាទុក្ខនោះគឺថា គាត់បានសន្មតដោយមានការភាន់ច្រឡំថា បើឯកសារណាមួយមិនត្រូវបានពោលយ៉ាងជាក់ច្បាស់ នៅក្នុងសាលក្រមទេនោះ ឬ មិនត្រូវបានពោលដល់នៅក្នុងផ្នែកជាក់លាក់ណាមួយនៃបញ្ហានោះទេ-

[116] *សូមមើល* វិធានផ្ទៃក្នុង, វិធាន ១០៤ ។ *សូមមើល ផងដែរ Rutaganda*, សាលដីកា, កថាខណ្ឌទី ២០ ("ជាគោលការណ៍ ការចោទប្រកាន់ថាមានការភាន់ច្រឡំផ្នែកច្បាប់ដែលមិនមានសក្ដានុពលក្នុងការបណ្ដាលឱ្យសេចក្ដីសម្រេចសួរដេញដោលដើម្បីឱ្យគេធ្វើការសម្រេចផ្ទុយ ឬពិនិត្យមើលឡើងវិញទេ នោះគឺមិនមែន[ការភាន់ច្រឡំ]ផ្នែកច្បាប់ទេ ។ ហេតុដូច្នេះ គេអាចបដិសេធចោលបាន") ។

នោះវាច្បាស់ជាមិនត្រូវបានគេធ្វើការពិចារណាទេ[117]។ ការពិចារណាបែបដូច្នេះ គឺគួរឱ្យមាន មន្ទិលនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌណាមួយក៏ដោយ ប៉ុន្តែដោយឡែកនេះ គឺមិនសមហេតុផលទេ ជាពិសេស ត្រង់កន្លែងដែលថាសំណុំរឿងលេខ០០១ មានទំហំធំ ហើយការពិតដែលថាមានឯកសារ ចំនួនរាប់រយ ឬប្រតិចារិកសវនាការជាច្រើនរយទំព័រ អាចនឹងត្រូវបានលើកឡើងជាច្រើនចំណុច។ តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលបានអនុវត្តនូវបទដ្ឋានដូចគ្នាស្តីពីការពិនិត្យបណ្តឹង ឧទ្ធរណ៍(សាទុក្ខ) ធ្លាប់បានពន្យល់ថា នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ចផ្តល់ នូវការវិនិច្ឆ័យមួយ ដែលមានការពិចារណារកហេតុផលរួចហើយ នោះមិនមែន មានន័យថា អង្គជំនុំជម្រះសាលាដំបូងនោះត្រូវតែនិយាយឱ្យច្បាស់ៗនូវ "គ្រប់ដំណាក់ការទាំងអស់ នៃការ ពិចារណារកហេតុផលរបស់ខ្លួន ឬក៏ត្រូវតែលើកឡើងនូវគ្រប់ភស្តុតាងនីមួយៗដែលខ្លួនបាន ពិចារណានោះឡើយ"[118]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR បានសម្រេចថា៖ "គេ ត្រូវធ្វើការសន្មតថា [ចំពោះបណ្តឹងឧទ្ធរណ៍] អង្គជំនុំជម្រះសាលាដំបូងបានធ្វើការវាយតម្លៃលើ គ្រប់ភស្តុតាងទាំងអស់ដែលបានដាក់បង្ហាញនៅចំពោះមុខខ្លួនរួចហើយ ដរាបណាឱ្យតែវាមិនមាន ការចង្អុលបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពិតជាមិនបានយកចិត្តទុកដាក់ទាំងស្រុងទៅលើ ផ្នែកនៃភស្តុតាងជាក់លាក់ណាមួយ"[119]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ដដែលនេះ ក៏បានបញ្ជាក់អះ

---

[117] *សូមមើល, ឧទា.* សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៦៩, ៧១ (ដោយបានលើកឡើងចោទថា អង្គជំនុំជម្រះសាលាដំបូងបានខកខានក្នុងការពិនិត្យលើភស្តុតាង "ដោះបន្ទុក" ស្តីពីយុត្តាធិការបុគ្គល ដែលមេធាវីការពារក្តីបានដាក់ជូន) ។

[118] *រដ្ឋអាជ្ញា ទល់នឹង Seromba*, សាលដីកា, ICTR-2001-66-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR, ថ្ងៃទី១២ មីនា ២០០៨, កថាខណ្ឌទី ៩៤ ។ *សូមមើលផងដែរ* សាលដីកាលើករណីរបស់ *Ndindabahizi*, កថាខណ្ឌទី ៧៥ ។ សាលដីកាលើករណីរបស់ *Kvočka*, កថាខណ្ឌទី ២៣ ។

[119] សាលដីកាលើករណីរបស់ *Ndindabahizi*, កថាខណ្ឌទី ៧៥ ។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Niyitegeka*, សាលដីកា, ICTR-96-14-A, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTR, ថ្ងៃទី៩ កក្កដា ២០០៤, កថាខណ្ឌទី ១២៤ (ដោយបានលើកឡើងថា "អង្គជំនុំជម្រះ

អាងផងដែរថា ដើមបណ្តឹងឧទ្ធរណ៍(សាទុក្ខ)ត្រូវទទួលបន្ទុកនៅក្នុងការបង្ហាញសក្ខីកម្មថា អង្គជំនុំជម្រះសាលាដំបូងពិតជាមិនបានយកចិត្តទុកដាក់ទៅលើផ្នែកនៃភស្តុតាងជាក់លាក់នោះឡើយ[120]។

៩៥. ដើមបណ្តឹងសាទុក្ខមិនបានពន្យល់ទេថាតើ គេអាចដឹងខុសត្រូវបានថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិនិត្យភស្តុតាងដែលទាក់ទងនឹងយុត្តាធិការបុគ្គល នៅចំពោះមុខខ្លួនបានតាមរបៀបណានោះ។ អង្គហេតុពិតតែមួយគត់គឺថា ការដែលអង្គជំនុំជម្រះសាលាដំបូង មិនយល់ស្របតាមជាមួយនឹងដើមបណ្តឹងសាទុក្ខអំពីយុត្តាធិការបុគ្គល នោះមិនមែនមានន័យថា អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំនៅក្នុងការពិចារណាភស្តុតាងនោះទេ។ តាមពិតទៅ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និង ICTR បានទទួលស្គាល់យ៉ាងជាប់លាប់ថា៖ "ភាគីណាមួយក៏ដោយមិនអាចគ្រាន់តែលើកសំអាងបណ្តឹងឧទ្ធរណ៍(សាទុក្ខ)ដែលខ្លួនមិនបានទទួលជោគជ័យនៅក្នុងអង្គជំនុំជម្រះសាលាដំបូងឡើងវិញជាដដែលម្តងទៀតបានឡើយ លើកលែងតែ ខ្លួនអាចបកស្រាយបង្ហាញបានថា ការច្រានចោលរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំអាងទាំងនោះបង្កើតបានជាការភាន់ច្រឡំមួយដែលនាំបណ្តាលឱ្យមានអន្តរាគមន៍ ពីសំណាក់អង្គជំនុំជម្រះសាលាឧទ្ធរណ៍"[121]។

---

សាលាដំបូងមិនចាំបាច់និយាយដោយច្បាស់ៗនៅក្នុងសាលក្រមរបស់ខ្លួននូវគ្រប់កត្តាទាំងអស់ ដែលខ្លួនបានពិចារណានៅក្នុងការបានឈានដល់ការរកឃើញអ្វីមួយនោះទេ ហើយថា អង្គជំនុំជម្រះមិនពិភាក្សាលើបញ្ហាណាមួយក្នុង សាលក្រម ដែលមិនបង្កើតបានជាការភាន់ច្រឡំដែរ") ។

[120] សាលដីកាលើករណីរបស់ *Rutuganda*, កថាខណ្ឌទី ៥៣៦ ("កាលណាភស្តុតាងមិនបានយោង ដល់សាលក្រមទេ នោះដើមបណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងពិតជាបានមិនយកចិត្តទុកដាក់ទៅលើវាទេ") ។

[121] សាលដីកាលើករណីរបស់ *Muvunyi*, កថាខណ្ឌទី ១១ ។ *សូមមើលផងដែរ* សាលដីកាលើករណីរបស់ *Nahimana,* កថាខណ្ឌទី ៣៩៥ ("ការបដិសេធធម្មតាមួយនៃ... ទៅលើការជំទាស់នានាមិនអាចនាំឱ្យមានជាសក្ខីកម្មពីការភាន់ច្រឡំ ដែលធ្វើឱ្យមោឃៈដល់សេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូងបានទេ ឬសក្ខីកម្មពីបុរេវិនិច្ឆ័យដែលប៉ះពាល់ដល់ការត្រៀមរៀបចំរបស់មេធាវីការពារដើមបណ្តឹងឧទ្ធរណ៍") ។

៥៦. លើសពីនេះទៀត សូម្បីតែគេមិនតម្រូវថាអង្គជំនុំជម្រះសាលាដំបូង ត្រូវតែពិភាក្សាលើគ្រប់ផ្នែកនៃភស្តុតាងទាំងអស់ក៏ដោយ ក៏វាជាក់ស្តែងណាស់ដែលថា សាលក្រមដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលដឹងឮ ព្រមទាំងបានយកចិត្តទុកដាក់ពីប្រភេទនៃអង្គហេតុទាំងឡាយ និងភស្តុតាងនានាដែលដើមបណ្តឹងសាទុក្ខបានចាត់ទុកថា អង្គជំនុំជម្រះសាលាដំបូង "នៅមិនទាន់បានដាក់បង្ហាញនៅឡើយ" នោះ[122]។ តាមការពិត នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានធ្វើការយោងយ៉ាងច្បាស់ៗណាស់ យ៉ាងហោចណាស់ក៏មានឯកសារចំនួនពីរ(២) ដែលដើមបណ្តឹងសាទុក្ខបានលើកឡើងដែរ[123]។ ដោយឡែក របាយការណ៍របស់លោក Craig C. Etcheson ដែលដើមបណ្តឹងសាទុក្ខបានពឹងផ្អែកលើយ៉ាងខ្លាំងនោះ ត្រូវបានលើកឡើងជាច្រើនចំណុចនៅក្នុងសាលក្រម[124]។ អង្គជំនុំជម្រះសាលាដំបូង ក៏បានយោងយ៉ាងច្បាស់ៗពីសារាចរណែនាំ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលដើមបណ្តឹងសាទុក្ខបានពោលដល់ផងដែ[125]។ លើសពីនេះទៀត ចំណុចសំខាន់ៗដែលដើមបណ្តឹងសាទុក្ខបានស្វែងរកធ្វើឱ្យមានការលេចឡើងនោះ គឺអង្គហេតុពិតដែលថាជនជាប់ចោទ មិនមែនជាផ្នែកមួយនៃថ្នាក់ជាន់ខ្ពស់បំផុតនៃរចនាសម្ព័ន្ធរបស់ បកក នោះទេ ហើយ

---

[122] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ៧២ (ចំណងជើង) ។

[123] អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY ធ្លាប់បានលើកឡើងថា ("ឯកសារយោងទៅលើផ្នែកជាក់លាក់មួយចំនួននៃសក្ខីកម្មរបស់សាក្សី គឺជាភស្តុតាង*មួយក្រឡេកម្តែក* - *prima facie* evidence ដែលអង្គជំនុំជម្រះសាលាដំបូងមានសមត្ថកិច្ចលើសក្ខីកម្មទាំងមូល និងយកមកធ្វើការពិចារណា") ។ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Miodrag Jokié*, សាលដីកាលើបណ្តឹងសាទុក្ខស្តីពីការផ្តន្ទាទោស, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, IT-01-42/1-A, ថ្ងៃទី៣០ សីហា ២០០៥, កថាខណ្ឌទី ៧៣។ ត្រូវអនុវត្តភាពសមហេតុសមផលដូចគ្នានេះដែរ កាលណាមានបញ្ហាណាមួយស្តីពីថាតើផ្នែកមួយនៃឯកសារជាក់លាក់ត្រូវបានពិចារណាដែរឬទេ ។

[124] *សូមមើល* សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ៨៥-៨៧, ៩០-៩២, ៩៤-៩៦, ៩៩, ១០៣, ១០៥-១០៦, ១០៩ ។

[125] *សូមមើល* សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ១០២ ។ ខណៈដែលអង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងពីការសួរចម្លើយជនជាប់ចោទកាលពីថ្ងៃទី២ មេសា ២០០៨ ដែលការសួរចម្លើយនេះត្រូវបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ ត្រង់កថាខណ្ឌទី៨៦ នោះខ្លួនបានកត់សម្គាល់យ៉ាងច្បាស់ៗថាខ្លួនបានប៉ាន់ប្រមាណទៅលើតម្លៃភស្តុតាងនៃចម្លើយរបស់ជនជាប់ចោទរួចហើយ ។ *សូមមើល* សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ៥០ ។

ថាដើមបណ្តឹងសាទុក្ខបានអនុវត្តតាមបញ្ជារបស់ថ្នាក់លើរបស់ខ្លួន[126] គឺត្រូវបានដាក់បញ្ចូលគ្នាទៅក្នុងការវិភាគរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីពិរុទ្ធភាពរបស់ដើមបណ្តឹងសាទុក្ខ[127]។

## ៤. សេចក្តីសន្និដ្ឋាន

៥៧. អាស្រ័យហេតុដូច្នេះ ដោយមានមូលហេតុទាំងអស់ដែលបានពិភាក្សានៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីនេះចោលទាំងស្រុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

126 ដើមបណ្តឹងសាទុក្ខក៏បានលើកឡើងផងដែរពីបញ្ហាស្តីពីកំរិតពិរុទ្ធភាព ដោយបានប្រៀបធៀបទៅនឹងប្រធានគុកដទៃទៀត ។ ឧទាហរណ៍ គាត់បានលើកស្នើឡើងថា ឧក្រិដ្ឋកម្មរបស់គាត់គឺមិនមានចេតនាទេ រីឯអំពើរបស់ប្រធានគុកដទៃទៀតគឺមានចេតនា ។ *សូមមើល* សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី, កថាខណ្ឌទី ២៥ ។ សូម្បីតែបញ្ហាស្តីពីឆន្ទៈដោយប្រៀបធៀប (comparative volition) របស់ពួកប្រធានគុកខ្មែរក្រហមក៏មានជាប់ទាក់ទងក៏ដោយ - ដែលករណីនេះមិនមែនដូច្នោះទេ - ក៏ដើមបណ្តឹងសាទុក្ខខកខានមិនបានលើកឡើងពីប្រភពច្បាប់ណាមួយដែលគាំទ្រដល់ការអះអាងរបស់គាត់ទេ ។ លើសពីនេះទៀត សូម្បីតែគេត្រូវសន្មតពីសច្ចៈសីលភាព (veracity) នៃចម្លើយដែលមិនមានការគាំទ្ររបស់ដើមបណ្តឹងសាទុក្ខក៏ដោយ - ត្រង់កថាខណ្ឌទី ២៣ នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី - ក៏"ចំនួនអ្នកទោសស្លាប់នៅមន្ទីរស-២១ តិចជាងចំនួនអ្នកទោសស្លាប់នៅគុកដទៃទៀត" ដែលដូចជាការលើកឡើងថាមន្ទីរស-២១ គឺជាគុកធម្មតា - គ្រាន់តែជាគុកធម្មតាមួយក្នុងចំណោមគុកជាច្រើនក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលនៃរបបខ្មែរក្រហម - នោះគឺជាការមួយដែលនាំឱ្យយល់ខុស និងមិនត្រឹមត្រូវទេ ។ *សូមមើលខាងលើ*, ផ្នែក ២.គ.ii, កថាខណ្ឌទី ៣៨,៤៦ ។

127 *សូមមើល, ឧទា.* សាលក្រមសំណុំរឿងលេខ ០០១, កថាខណ្ឌទី ១៦៨-១៦៩ (ដោយបានទទួលស្គាល់ថា ជាទូទៅ ថ្នាក់លើទាំងឡាយរបស់ជនជាប់ចោទបានធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធទៅនឹងថាតើនរណាដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១ ក៏ប៉ុន្តែក៏បានទទួលស្គាល់ផងដែរថាមានភស្តុតាងបញ្ជាក់ថា គេបានស្វែងរកយោបល់របស់ជនជាប់ចោទ ហើយថ្នាក់លើបានធ្វើតាមយោបល់នោះ) ។ កថាខណ្ឌទី ៣២៨ (ដោយបានទទួលស្គាល់ថា ជនជាប់ចោទបានរាយការណ៍ជូនទៅកាន់ថ្នាក់លើខ្ពស់ជាងគាត់ នៅក្នុងពួកមេដឹកនាំ បកក គឺថាពួកសមាជិកនៃគណៈអចិន្ត្រៃយ៍) ។ អង្គហេតុដែលថាចំណុចទាំងនេះមិនត្រូវបានពោលដាក់លាក់នៅក្នុងផ្នែកយុត្តាធិការបុគ្គលនៃសាលក្រម គឺដោយខ្លួនវាផ្ទាល់ មិនអាចបង្ហាញថាវាជាការភាន់ច្រឡំមួយខាងផ្នែកអង្គជំនុំជម្រះសាលាដំបូងនោះបានទេ ។